■ គម្រោងគាំទ្រពាណិជ្ជូបនីយកម្មស្រូវអង្ករកម្ពុជា [SCCRP]

[AFD Grant - CKH-1077-01-S និង CKH-1077-02-T]

AFD

ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (SNEC)

ករណីសិក្សា #5

# វេទិកាស្តីពីពាណិជ្ជកម្មស្រូវ

ថ្ងៃទី 25 ខែកញ្ញា ឆ្នាំ 2017

អ្នកនិពន្ធ៖ CHRISTOPHE GOOSSENS (ADG), PHAT SOPHANY (AVSF), សមាគម AVSF-CIRD-ADG[1]

និង JEAN-MARIE BRUN (IRAM)[2]

AVSF CIRD adg iram

## មាតិកា

1. ទិដ្ឋភាពរួម / ការបរិយាយខ្លីអំពីវេទិកាស្តីពីពាណិជ្ជកម្មស្រូវ ........ 2
2. ដើមកំណើតសកម្មភាព ........ 3
3. ភាគីពាក់ព័ន្ធដែលចូលរួម ........ 5
4. ដំណើរការអនុវត្តន៍ ........ 5
5. លទ្ធផល និងស្ថានភាពប្រតិបត្តិការ ........ 10
6. ការវិភាគផ្នែកសេដ្ឋកិច្ច ........ 11
7. ការគាំទ្រវេទិកា PTP បន្ថែមទៀត និងស្ថានភាពសម្រាប់និរន្តរភាព ........ 15

## អក្សរកាត់

| | |
|---|---|
| AC | សហករណ៍កសិកម្ម |
| AFD | *ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង* |
| CFAP | សហព័ន្ធសមាគមកសិករកម្ពុជានៃអ្នកផលិតកសិកម្ម |
| CRF | សហព័ន្ធស្រូវអង្ករកម្ពុជា |
| DACP | នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម (/MAFF) |
| FAEC | សហព័ន្ធសមាគមជំរុញសហគ្រាសកសិកម្មជាលក្ខណ:គ្រួសារនៅកម្ពុជា |
| FWUC | សហគមន៍កសិករប្រើប្រាស់ទឹក |
| ICT | បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ |
| ISC | មជ្ឈមណ្ឌលសេវាកម្មធារាសាស្ត្រ |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| NF3 | វេទិកាសហព័ន្ធអង្គការកសិករថ្នាក់ជាតិ |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| PSG | ក្រុមលក់ស្រូវ |

[1] www.avsf.org ; www.cird.org.kh ; www.ong-adg.be

[2] www.iram-fr.org

SCCRP ■ ករណីសិក្សា

| | | | |
|---|---|---|---|
| FCFD | សហព័ន្ធអង្គការកសិករកម្ពុជាដើម្បីអភិវឌ្ឍន៍ | PTP | វេទិកាស្ដីពីពាណិជ្ជកម្មស្រូវ |
| FNN | បណ្ដាញកសិករ និងធម្មជាតិ | SNEC | ឧត្ដមក្រុមប្រឹក្សាសេដ្ឋកិច្ច |
| FO | អង្គការកសិករ | SCCRP | គម្រោងគាំទ្រពាណិជ្ជូបនីយកម្មស្រូវអង្ករកម្ពុជា |
| FWN | បណ្ដាញកសិករ និងទឹក | | |

# 1. ទិដ្ឋភាពរួម / ការបរិយាយខ្លីអំពីវេទិកាស្ដីពីពាណិជ្ជកម្មស្រូវ

ករណីសិក្សានេះធ្វើឡើងដើម្បីកត់ត្រាការរៀបចំវេទិកាស្ដីពីពាណិជ្ជកម្មស្រូវ (PTP) ដែលបង្កើតឡើងតាមគម្រោងគាំទ្រពាណិជ្ជូបនីយកម្មស្រូវអង្ករកម្ពុជា (SCCRP)[3] ដើម្បីបង្កើត និងពង្រឹងបណ្ដាញរវាងអង្គការកសិករ (FO) និងអ្នកទិញស្រូវអង្ករវិស័យឯកជននៅប្រទេសកម្ពុជា។ គម្រោង SCCRP បានគាំទ្រដល់អង្គការពាណិជ្ជកម្ម FO ក្នុងទម្រង់ជាសហករណ៍កសិកម្ម (AC) ឬសហគមន៍កសិករប្រើប្រាស់ទឹក (FWUC) ដើម្បីបំពេញតួនាទីរបស់ខ្លួនជាភាគីពាក់ព័ន្ធសេដ្ឋកិច្ចនៅក្នុងសង្វាក់តម្លៃស្រូវអង្ករ។ នៅក្នុងរយៈពេលបីឆ្នាំដំបូងនៃការអនុវត្តគម្រោង អង្គការ FO មួយចំនួនបានទទួលជោគជ័យក្នុងការរៀបចំក្រុមលក់ស្រូវ (PSG) ដើម្បីប្រមូលស្រូវពីសមាជិករបស់ខ្លួន និងការប្រមូលផ្ដុំអ្នកទិញការចរចាលើស្ថានភាពទិញស្រូវ ព្រមទាំងការរៀបចំកិច្ចសន្យា និងកិច្ចព្រមព្រៀងលក់។ ដើម្បីបង្កើនបទពិសោធន៍ទាំងនេះ និងពង្រីកអង្គការ FO ឱ្យបានកាន់តែច្រើន គេបានសម្រេចចិត្តរៀបចំវេទិកា B2B ដោយផ្ដល់នូវព័ត៌មានលម្អិតអំពីអ្នកលក់ស្រូវ (អង្គការ FO) និងអ្នកទិញស្រូវ (ម្ចាស់រោងម៉ាស៊ីនកិនស្រូវ ក្រុមហ៊ុននាំចេញ ...)។ គោលបំណងដើមគឺដើម្បីអាចឱ្យអង្គការ FO អាចទាក់ទាញសហគ្រាសម៉ាស៊ីនកិនស្រូវធំៗ ដែលអាចផ្ដល់តម្លៃខ្ពស់ដល់ស្រូវមានគុណភាពដើម្បីទទួលយកការបន្ថែមតម្លៃសម្រាប់កសិករ។

វេទិកា PTP នេះ ជាឧបករណ៍ផ្គូផ្គងអាជីវកម្មមួយជួយដល់ឧបករណ៍ផ្សេងទៀតដែលអនុវត្តដោយគម្រោង SCCRP ដោយមានគោលដៅរួម គឺគាំទ្រដល់កំណើនសង្វាក់តម្លៃស្រូវអង្ករជារួម និងដោយឡែកគាំទ្រដល់កសិករកម្ពុជាឱ្យជឿជាក់លើអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចដែលបានមកពីការអភិវឌ្ឍទីផ្សារស្រូវអង្ករ។ ទាំងនេះ គឺបានមកពីការអន្តរាគមន៍គាំទ្រចម្រុះសម្រាប់អង្គការ FO ដើម្បីទទួលបានប្រសិទ្ធពលបច្ចេកទេស និងអាជីវកម្ម (សម្រួលដល់ការទទួលបានហិរញ្ញវត្ថុ សម្រួលដល់ការរៀបចំកិច្ចសន្យា និងជំនួយបច្ចេកទេសដល់ការរៀបចំការផ្គត់ផ្គង់...) ដោយរាប់បញ្ចូលទាំងការចូលរួមរបស់ពួកគេនៅក្នុងអន្តរវិជ្ជាជីវៈនៃអនុវិស័យស្រូវអង្កររបស់សហព័ន្ធស្រូវអង្ករកម្ពុជា (CRF)។ ដំបូងឡើយវេទិកា PTP ត្រូវបានបង្កើតឡើងក្នុងគោលបំណងស្នើជាសេវាកម្មសហព័ន្ធ CRF ដល់សមាជិករបស់ខ្លួនឱ្យចូលរួមក្នុងសហគ្រាស និងអង្គការ FO ដែលប្រតិបត្តិការនៅក្នុងសង្វាក់តម្លៃស្រូវអង្ករ។ គួរឱ្យសោកស្ដាយ គោលបំណងនេះមិនបានលេចជារូបរាងទេ ដោយសារសហព័ន្ធ CRF សម្រេចចិត្តមិនសហការ ព្រោះគម្រោងរបស់វេទិកា PTP នេះបានឈានដល់ដំណាក់កាលអនុវត្តទៅហើយ។ ដោយសារតែវេទិកា PTP ទើបតែបានបង្កើតឡើង ដូច្នេះឯកសារនេះគឺគ្រាន់តែផ្ដោតសំខាន់លើចំណេះដឹងដែលគម្រោង SCCRP ទទួលបាន នៅពេលបង្កើត និងប្រតិបត្តិការវេទិកា PTP ដោយមានបំណង៖

- ផ្ដល់ព័ត៌មានអំពីវេទិកាស្ដីពីពាណិជ្ជកម្មស្រូវសម្រាប់គោលបំណងសិក្សារួម
- ផ្ដល់អនុសាសន៍អនុវត្តសម្រាប់ការគាំទ្រនាពេលខាងមុខ ដើម្បីរក្សានិងបង្កើនការផ្ដួចផ្ដើមគំនិត

[3] គម្រោង SCCRP គឺជាគម្រោងរយៈពេល 5 ឆ្នាំ ដែលសម្របសម្រួលដោយឧត្ដមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (SNEC) ផ្ដល់មូលនិធិដោយ *ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង* (AFD) និងផ្ដល់ជំនួយបច្ចេកទេសដោយ NIRAS/IRAM និងសមាគម AVSF/CIRD/ADG ។

ការដាក់ពាក្យតាមអេឡិចត្រូនិកចូលរួមក្នុងវេទិកានេះមាននៅ៖ http://paddycambodia.org (តម្រូវឱ្យចុះឈ្មោះចូល និងបញ្ចូលពាក្យសម្ងាត់ ដើម្បីចូលប្រើប្រាស់ទំព័រនេះ)។

វេទិកា PTP ត្រូវបានបង្កើតឡើងនៅឆ្នាំ 2016 នៅពេលឈានដល់ការប្រមូលផលរដូវសំណើម ដោយមានអង្គការ FO ចំនួន 94 បានចុះឈ្មោះជាអ្នកប្រើនៅក្នុងប្រព័ន្ធ ហើយមានអង្គការកសិករចំនួន 32 បានបង្ហោះការប្រកាសស្ដីពីការប្រមូលផលដែលបានព្យាករណ៍ និងសមត្ថភាពផ្គត់ផ្គង់ស្រូវរបស់ខ្លួន។ អង្គការ FO ចំនួន 92 ក្នុងចំណោម 94 គឺជាសមាជិកយ៉ាងហោចណាស់មួយក្នុងសហព័ន្ធអង្គការ FO ថ្នាក់ជាតិ (សហព័ន្ធ FAEC សហព័ន្ធ FCFD ឬបណ្ដាញ FWN) ដែលផ្ដល់ការជំនួយ និងការការពារដល់ពួកគេ ដើម្បីធានាគុណភាពនិងភាពអាចជឿជាក់បានរបស់ព័ត៌មានដែលបានបង្ហោះ។

មានម្ចាស់រោងម៉ាស៊ីនកិនស្រូវ/ក្រុមហ៊ុននាំចេញជាង 40 បានចុះឈ្មោះនៅក្នុងប្រព័ន្ធ និងអាចមើលឃើញការប្រកាសរបស់អង្គការ FO ទាំងអស់អំពីវេទិកាលើអ៊ីនធឺណិត។ ពួកគេអាចដាក់តាមប្រភេទ ឬច្រោះការប្រកាសទាំងនេះដោយផ្អែកលើលក្ខណវិនិច្ឆ័យនានា (ប្រភេទស្រូវ បរិមាណដែលមាន ទីតាំងភូមិសាស្ត្រ...)។ ពួកគេក៏អាចទទួលបានការជូនដំណឹងតាមអ៊ីមែលនិង/ឬ SMS ផងដែរ នៅពេលណាដែលអង្គការ FO បង្ហោះការប្រកាសថ្មី ហើយពួកគេអាចជ្រើសរើសតម្រង (ដូចរៀបរាប់ខាងលើ) ដើម្បីទទួលតែការប្រកាសណាដែលពួកគេចាប់អារម្មណ៍ប៉ុណ្ណោះបាន។

## 2. ដើមកំណើតសកម្មភាព

ដោយដឹងអំពីតម្រូវការក្នុងការកែលម្អប្រសិទ្ធភាពរបស់ទីផ្សារផ្គត់ផ្គង់ស្រូវដាច់ដោយឡែក គម្រោង SCCRP បានកំណត់ស្ថានភាពនានា ដែលទំនាក់ទំនងអាជីវកម្មត្រូវបានបង្កើតឡើងតាមប្រភេទផ្គូផ្គងអាជីវកម្មផ្សេងៗគ្នាដោយ៖

- សម្របសម្រួលដល់ការចូលរួមរបស់អង្គការ FO នៅក្នុងសមធម៌ពាណិជ្ជកម្ម និងពិព័រណ៍ដូចជា បុណ្យស្រូវអង្ករអន្តរជាតិ និងវេទិកាស្ដីពីស្រូវអង្ករថ្នាក់ជាតិ
- រៀបចំកិច្ចប្រជុំអ្នកលក់/អ្នកទិញ រវាងអង្គការ FO និងម្ចាស់រោងម៉ាស៊ីនកិនស្រូវធំ និងក្រុមហ៊ុននាំចេញ ដូចជា ក្រុមហ៊ុនវិនិយោគអង្ករបាត់ដំបង (BRICO) ក្រុមហ៊ុនអេមរុ ក្រុមហ៊ុនហ្គោលដេនរ៉ាយស៍ ក្រុមហ៊ុន បាយ័នហេរិថេច និងក្រុមហ៊ុនជាច្រើនទៀត
- បង្កើតកូនសៀវភៅស្ដីពីទិន្នន័យអង្កររបស់អង្គការ FO និងព័ត៌មានទំនាក់ទំនង
- បង្កើត និងចេញផ្សាយការប្រកាសលក់ស្រូវ និងផែនទីឌីជីថលនៃគម្រោងធារាសាស្ត្រដ៏ធំ ដើម្បីធ្វើផែនការ និងរៀបចំការផលិត និងការប្រមូលផលនៃក្រុមលក់ស្រូវស្នឹងជីនិត (PSG)
- បង្កើត និងប្រតិបត្តិវេទិកាស្ដីពីពាណិជ្ជកម្មស្រូវ (PTP)

វេទិកា PTP ចាប់ផ្ដើមដំបូងចេញពីបទពិសោធន៍នៅក្នុងកូនសៀវភៅស្ដីពីផលិតកម្មរបស់អង្គការ FO និងការប្រកាសលក់ស្រូវ ព្រមទាំងនៅលើផែនទីឌីជីថលនៃស្នឹងជីនិតរបស់ក្រុម PSG ។ សិក្ខាសាលាស្ដីពីការប្រឹក្សាយោបល់របស់ភាគីពាក់ព័ន្ធត្រូវបានរៀបចំឡើង (នៅដំណាក់កាលនោះជាមួយនឹងសហព័ន្ធ CRF និងអង្គការ FO) ដើម្បីកំណត់ភាពជោគជ័យ និងបរាជ័យនៃការប្រើប្រាស់ឧបករណ៍ទាំងនេះ ក៏ដូចជាបង្កើតការកែសម្រួលចាំបាច់ដែលនាំឱ្យមានការរៀបចំវេទិកា PTP ។

## 2.1. កូនសៀវភៅស្ដីពីទិន្នន័យផលិតកម្មអង្ករ និងព័ត៌មានទំនាក់ទំនងរបស់អង្គការ FO

កូនសៀវភៅនេះបានបោះពុម្ពផ្សាយដោយសហព័ន្ធ FAEC សហព័ន្ធ FCFD និងបណ្ដាញ FWN នៅខែតុលា ឆ្នាំ 2015 ដែលជាការបង្កើតមធ្យោបាយស្វែងរកអ្នកទិញសក្ដានុពលនៃការប្រមូលផលស្រូវនារដូវវស្សាចាប់ពីឆ្នាំ 2015 ដល់ខែមីនា ឆ្នាំ 2016 អង្គការ FO នីមួយៗដែលមានចំនួន 44 មកពីខេត្តចំនួន 10 បានចេញផ្សាយព័ត៌មាននៅលើទំព័រមួយក្នុងអង្គការ FO មួយរួមមាន៖




- ឈ្មោះ និងព័ត៌មានទំនាក់ទំនងលម្អិតរបស់អង្គការ FO
- ប្រភេទគ្រាប់ស្រូវដែលបានដាំដុះ និងបរិមាណសក្ដានុពល
- រដូវប្រមូលផល
- ភាពអាចប្រើប្រាស់ផ្លូវ និងភាពអាចរកបានឃ្លាំងផ្ទុក និងធារាសាស្ត្រ។

កូនសៀវភៅចំនួន 1,000 ក្បាលត្រូវបានបោះពុម្ព និងចែកជូនអ្នកតំណាងរបស់អង្គការម្ចាស់រោងម៉ាស៊ីនកិនស្រូវ និងសមាជិកសហព័ន្ធ CRF ។

នៅដើមឆ្នាំ 2016 មុនពេលរៀបចំសម្រាប់រដូវប្រមូលផលស្រូវបន្ទាប់ មានការវាយតម្លៃថាមានសហគមន៍កសិករតែមួយប៉ុណ្ណោះក្នុងខេត្តបាត់ដំបងដែលមានម្ចាស់រោងម៉ាស៊ីនកិនស្រូវមួយកន្លែងបានទាក់ទង ប៉ុន្តែមានការយឺតពេលសម្រាប់ផ្គត់ផ្គង់ការប្រមូលស្រូវរបស់ពួកគេក្នុងឆ្នាំ 2015 ។ បន្ទាប់ពីទទួលស្គាល់លទ្ធផលនេះ សិក្ខាសាលាពិគ្រោះយោបល់ជាមួយភ្នាក់ងារពាក់ព័ន្ធត្រូវបានរៀបចំឡើងរវាងម្ចាស់រោងម៉ាស៊ីនកិនស្រូវ និងអ្នកតំណាងអង្គការ FO អំឡុងពេលធ្វើការសម្រេចប្ដូរទៅជាវេទិកាទិន្នន័យតាមអ៊ីនធឺណិត។

## 2.2. ការប្រកាសលក់ស្រូវ និងផែនទីឌីជីថល ក៏ដូចជាការប្រកាសលក់ស្រូវមុនការប្រមូលផលរបស់ស្ទឹងជីនិតនៃក្រុម PSG

សហគមន៍កសិករប្រើប្រាស់ទឹក (FWUC) របស់គម្រោងធារាសាស្ត្រស្ទឹងជីនិតនៅខេត្តកំពង់ធំ ដែលរៀបចំឡើងដោយក្រុមលក់ស្រូវ (PSG) បានចាប់ផ្ដើមនៅក្នុងឆ្នាំ 2014 ដោយកែលម្អផលិតកម្មគ្រាប់អង្ករ*ផ្កាវិជ្ជលក*ដែលមានគុណភាពល្អជាប្រភេទអង្ករ (ផ្កាម្លិះ) ក្រអូបគ្រាប់វែងដែលមានតម្លៃទីផ្សារល្អ។ ក្នុងឆ្នាំ 2015 គេបានប៉ាន់ស្មានថា ស្រូវដែលមានគុណភាពល្អច្រើនជាង 500 តោន អាចត្រូវបានប្រមូលពីគ្រាប់ពូជទាំងនេះ។ សហគមន៍ FWUC ដែលមានជំនួយផ្នែកបច្ចេកទេសពីមជ្ឈមណ្ឌលសេវាកម្មធារាសាស្ត្រ (ISC) បានសម្រេចកែសម្រួលការប្រកាសលក់ស្រូវជាមួយនឹងផែនទីឌីជីថលនៃតំបន់ផលិតកម្ម (ក្នុងគម្រោងធារាសាស្ត្រ) ដោយបញ្ជាក់ថាស្រូវត្រូវបានដាំដុះពីគ្រាប់ពូជល្អ និងផ្ដល់ជូនព័ត៌មានលម្អិតស្ដីពីបរិមាណដែលបានរំពឹងទុក ដែលត្រូវផ្គត់ផ្គង់ ចាប់ពីថ្ងៃទី 6 ខែវិច្ឆិកា ដល់ទី 18 ខែវិច្ឆិកា (50 ទៅ 65 តោនក្នុងការបញ្ជូនម្ដងសម្រាប់ការប្រមូលសរុបចំនួន 9 ថ្ងៃ)។ ក្នុងករណីនេះ ព័ត៌មានដែលផ្ដល់ឱ្យគឺមានលក្ខណៈច្បាស់លាស់ជាងព័ត៌មានក្នុងកូនសៀវភៅរបស់សហព័ន្ធអង្គការ FO ៖ វាជាព័ត៌មានដែលទើបតែបានប្រមូលនៅមុនពេលប្រមូលផល ដោយមានការវាយតម្លៃភ្លាមៗ



លើបរិមាណជាក់ស្តែងដែលមាន និងនៅថ្ងៃប្រមូលផល ព្រមទាំងមានសូចនាករនៃគុណភាពដែលបានរំពឹងទុក។ ការប្រកាសនេះត្រូវបានផ្សព្វផ្សាយដោយផ្ទាល់ទៅអ្នកទិញល្បីៗមួយចំនួន និងតាមរយៈសហព័ន្ធ CRF ផងដែរ។

ការវាយតម្លៃមួយបានបញ្ជាក់ថា ការប្រកាសពីផែនទីឌីជីថល (ដែលគាំទ្រដោយសេវាកម្មភស្តុភារមានបង្កប់ផែនការលម្អិតនៃបរិមាណប្រមូល និងចំណុចប្រមូល) បាននាំឱ្យមានកិច្ចព្រមព្រៀងផ្នែកពាណិជ្ជកម្មជាមួយម្ចាស់រោងម៉ាស៊ីនកិនស្រូវ ហើយវាអនុញ្ញាតឱ្យអ្នកផលិតទទួលបានតម្លៃល្អសម្រាប់ស្រូវដែលមានគុណភាពល្អ ដែលនាំឱ្យមានការលើកទឹកចិត្តដល់កសិករ ដើម្បីបន្តការវិនិយោគលើគុណភាពនៅឆ្នាំបន្ទាប់។ នេះក៏បាននាំឱ្យមានការកែលម្អភាពដែលអាចមើលឃើញរបស់សហគមន៍ FWUC ទៅអ្នកផ្តល់សេវាឧបករណ៍ប្រមូលផលដែលបានទាក់ទងមកសហគមន៍ FWUC ដើម្បីស្នើតម្លៃគួរឱ្យចាប់អារម្មណ៍សម្រាប់សេវាកម្មរបស់ពួកគេ។

## 3. ភាគីពាក់ព័ន្ធដែលចូលរួម

វេទិកាពាណិជ្ជកម្មស្រូវចូលរួមដោយក្រុមភ្នាក់ងារពាក់ព័ន្ធចំនួនប្រាំសំខាន់ៗដូចខាងក្រោម៖

**តារាងទី 1៖ ភ្នាក់ងារពាក់ព័ន្ធដែលបានចូលរួមក្នុងវេទិកាពាណិជ្ជកម្មស្រូវ**

| ភ្នាក់ងារពាក់ព័ន្ធ | តួនាទី / មុខងារ | ការងារសំខាន់ៗ |
|---|---|---|
| អង្គការកសិករចំនួន 94 (FO) | ការប្រមូល | រៀបចំផលិតកម្មស្រូវ និងការផ្គត់ផ្គង់<br>ប្រមូល/ បង្កើត និងផ្តល់ទិន្នន័យស្តីពីការរំពឹងទុកផ្គត់ផ្គង់ស្រូវ |
| សហព័ន្ធ FO ចំនួន 3 (FAEC, FCFD, FWN) | ជំនួយផ្នែកបច្ចេកទេស/អ្នកសម្របសម្រួល | ផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់ FO ដើម្បីធានាភាពត្រឹមត្រូវរបស់ទិន្នន័យ<br>កែសម្រួល ផ្សព្វផ្សាយ និងតាមដានការប្រកាសលក់ស្រូវអង្ករជំនួសមុខឱ្យសមាជិករបស់ពួកគេ |
| ម្ចាស់រោងម៉ាស៊ីនកិនស្រូវ 40 / ក្រុមហ៊ុននាំចេញ | អ្នកទិញ | ផ្តល់តម្រូវការសម្រាប់ការរៀបចំ<br>ប្រភព និងទិញស្រូវអង្ករនៅមូលដ្ឋានរបស់ FO |
| ក្រុមប្រឹក្សា SCCRP | ជំនួយការផ្នែកបច្ចេកទេស | ជំនួយការផ្នែកបច្ចេកទេសទៅសហព័ន្ធ FO<br>ការសម្របសម្រួលនៃការពិគ្រោះយោបល់របស់ភ្នាក់ងារពាក់ព័ន្ធ<br>ការគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់ដំណើរការ |
| ក្រុមហ៊ុន Proact IT | សេវាកម្មឌីហ្សាញវិបសាយ | ការឌីហ្សាញ និងការបង្កើតវិបសាយ |

## 4. ដំណើរការអនុវត្តន៍

ដំណាក់កាលនៃដំណើរការសំខាន់ៗចំនួនបួនក្នុងការបង្កើត អភិវឌ្ឍ និងប្រតិបត្តិការវេទិកាស្តីពីពាណិជ្ជកម្មស្រូវគឺ៖

### 4.1. សិក្ខាសាលាស្តីពីការពិគ្រោះយោបល់របស់ភាគីពាក់ព័ន្ធ សម្រាប់ការអភិវឌ្ឍវេទិកាតាមអ៊ីនធឺណិត៖

សិក្ខាសាលាលើកទី 1 ត្រូវបានសហការរៀបចំឡើងដោយគម្រោង SCCRP និងសហព័ន្ធ CRF ដោយមានការចូលរួមពីសហព័ន្ធអង្គការ FO នៅថ្ងៃទី 4 ខែឧសភា ឆ្នាំ 2016 ។ គោលបំណងនៃសិក្ខាសាលានេះមានលក្ខណៈទូលំទូលាយជាងមុនដែលមានគោលគំនិតនៃវេទិកាស្តីពីពាណិជ្ជកម្មស្រូវ (រួមមានការគាំទ្រផ្សេងៗដល់ទំនាក់ទំនងពាណិជ្ជកម្មរវាងអង្គការ FO និងរោងម៉ាស៊ីនកិនស្រូវ ដូចជា ការគាំទ្រដល់ការបង្កើតផលិតកម្មកសិកម្មតាមកិច្ចសន្យា) ប៉ុន្តែកិច្ចប្រជុំ

សិក្ខាសាលានេះធ្វើឡើងដើម្បីទទួលបានព័ត៌មានរហ័ស និងការស្ទង់មតិដែលបានបញ្ជាក់ពីចំណាប់អារម្មណ៍របស់ម្ចាស់រោងម៉ាស៊ីនកិនស្រូវ សម្រាប់វេទិកាព័ត៌មានតាមអ៊ីនធឺណិតដែលផ្តល់ការប្រកាសមុនប្រមូលផលស្តីពីភាពអាចរកបានស្រូវជាមួយអង្គការ FO ។

នៅថ្ងៃទី 21 ខែកញ្ញា ឆ្នាំ 2016 សិក្ខាសាលាស្តីពីការពិគ្រោះយោបល់របស់ភាគីពាក់ព័ន្ធលើកទី 2 ត្រូវបានសហការរៀបចំដោយគម្រោង SCCRP និងសហព័ន្ធ CRF ពោលគឺមានចំនួន 64 នាក់ដែលមកពីសហព័ន្ធអង្គការ FO រោងម៉ាស៊ីនកិនស្រូវ/ក្រុមហ៊ុននាំចេញ សហព័ន្ធ CRF គម្រោង SCCRP, VSO, IFAD ក្រសួង MAFF និងអ្នកផ្តល់សេវាកម្មព័ត៌មានវិទ្យា បានស្វែងរកនិងពិភាក្សាយ៉ាងជ្រាលជ្រៅអំពីការដំឡើងវេទិកានេះនៅលើអ៊ីនធឺណិត។

សិក្ខាសាលានេះមានគោលបំណងចំនួនបួន៖ (1) ដើម្បីណែនាំពីតួនាទីដែលអាចធ្វើបានរបស់សហព័ន្ធ CRF ក្នុងការសម្របសម្រួលជាមួយវេទិកា PTP (2) ដើម្បីបញ្ជាក់អំពីព័ត៌មានដែលត្រូវការដោយរោងម៉ាស៊ីនកិនស្រូវ (3) យល់ព្រមលើខ្លឹមសារ និងការរៀបចំព័ត៌មានដែលអង្គការ FO គួរផ្តល់ឱ្យ និង (4) ដើម្បីកែសម្រួលឧបករណ៍ឌីជីថលដែលត្រូវប្រើ និងបង្កើត ព្រមទាំងមុខងាររបស់ប្រព័ន្ធផងដែរ។

ជម្រើសចំនួនបីត្រូវបានស្នើឡើង៖

- ជម្រើសទី 1៖ (ចាំបាច់ខ្លាំង) តារាងទិន្នន័យ excel មួយដែលបានធ្វើបច្ចុប្បន្នភាពក្នុងពេលវេលាជាក់ស្តែង និងដែលបានចែករំលែកតាមឧបករណ៍ដូចជា Drop Box ឬសេវាកម្មសមមូលផ្សេងទៀតដែលអនុញ្ញាតឱ្យកែសម្រួលលើអ៊ីនធឺណិត និងចែករំលែកការប្រើប្រាស់ទៅអ្នកប្រើ (ម្ចាស់រោងម៉ាស៊ីនកិនស្រូវ) ដើម្បីពិគ្រោះយោបល់ និងតម្រៀប/ច្រោះទិន្នន័យ។ ជម្រើសនេះជាចាំបាច់បំផុត មិនសម្រាប់តែផ្តល់ភាពងាយស្រួលដល់អ្នកប្រើប៉ុណ្ណោះទេ ប៉ុន្តែត្រូវបានស្នើដើម្បីអនុវត្តសម្រាប់ការប្រមូលផលប្រភេទស្រូវក្រអូបខាងមុខនេះ ក្នុងករណីដំណោះស្រាយច្រើនផ្សេងទៀតមិនអាចបង្កើតឡើងទាន់ពេលវេលា។
- ជម្រើសទី 2៖ ការប្រើវេទិកាដែលមានស្រាប់ (ដូចជា ពាណិជ្ជកម្មអេឡិចត្រូនិក ឬវេទិកាបណ្តាញសង្គម) ដើម្បីបង្ហោះការផ្តល់ជូនស្រូវជាមួយនឹងការបង្កើតជម្រើសបន្ថែមតែប៉ុណ្ណោះ "plug-in" ដើម្បីសម្រួលឧបករណ៍និងតម្រូវការជាក់លាក់របស់យើង។
- ជម្រើសទី 3៖ ការបង្កើតកម្មវិធី/ប្រព័ន្ធចាំបាច់ជាក់លាក់មួយ ដែលលៃតម្រូវទៅតាមតម្រូវការរបស់អង្គការ FO និងម្ចាស់រោងម៉ាស៊ីនកិនស្រូវ។

ក្រុមការងារត្រូវបានរៀបចំឡើងសម្រាប់ការពិភាក្សា ហើយលក្ខណៈខាងក្រោមនេះត្រូវបានជំនួស៖

- លក្ខណៈវិនិច្ឆ័យលើការប្រមូលទិន្នន័យគឺមានភាពជាក់លាក់ជាងមុន (ប្រភេទស្រូវ ពូជ បរិមាណ ការចាប់ផ្តើម/បញ្ចប់ គុណភាព ទីតាំង បុគ្គលិកទំនាក់ទំនង និងឯកសារភ្ជាប់ព័ត៌មានផ្សេងទៀត)
- ការធានាគុណភាពស្រូវអាចអនុវត្តលើការប្រកាសក្រោយប្រមូលផល សម្រាប់ក្រុមស្រូវមួយចំនួនដែលបានកំណត់លក្ខណៈពិសេសលម្អិតអំពីគុណភាពរួចរាល់ហើយ
- ការប្រមូលទិន្ន័យដែលជឿជាក់បានគឺពិបាកនៅពេលចាប់ផ្តើម តែវាអាចងាយស្រួលនៅក្នុងឆ្នាំបន្ទាប់ ហើយសហព័ន្ធអង្គការ FO ទទួលខុសត្រូវលើការគាំទ្រដល់មុខងាររបស់សហគមន៍សហករណ៍

សិក្ខាសាលានេះបានជួយបញ្ជាក់អំពីគោលបំណង និងមុខងារផ្សេងៗរបស់វេទិកា PTP ប៉ុន្តែក៏ផ្តោតលើសំណួរបឋមសំខាន់ៗទាក់ទងនឹងដំណើរការក្នុងការប្រមូលផល និងបញ្ចូលព័ត៌មានទៅក្នុងប្រព័ន្ធ ព្រមទាំងបែបបទដែលរំពឹងទុក

សម្រាប់អ្នកប្រើប្រាស់ស្តីពីផ្នែកអ្នកទិញ។ ជាពិសេស ប្រសិនបើម្ចាស់រោងម៉ាស៊ីនកិនស្រូវអាចទទួលបានតែព័ត៌មានពីការតភ្ជាប់ទៅវេទិកា និងការស្វែងរកការបង្ហោះនានាដែលពាក់ព័ន្ធទៅនឹងរោងម៉ាស៊ីនកិនស្រូវ (ដូចដែលវាត្រូវបានដឹងជាមុន) នោះហានិភ័យនៃការប្រើប្រាស់កម្រិតទាបត្រូវបានកំណត់ (ឧទាហរណ៍៖ ចំនួនម្ចាស់រោងម៉ាស៊ីនកិនស្រូវទាបដែលតភ្ជាប់ទៅពួកគេ និង/ឬការតភ្ជាប់មានកម្រិតប្រេកង់ទាប)។ យុទ្ធសាស្ត្រ "កម្លាំងជំរុញ" មួយត្រូវបានកំណត់ថាមានប្រសិទ្ធភាពច្រើន ដើម្បីបញ្ជូនព័ត៌មានទៅដល់ម្ចាស់រោងម៉ាស៊ីនកិនស្រូវដោយមានការជូនដំណឹងតាមអ៊ីមែល ឬសារ SMS ទៅពួកគេ ក៏ប៉ុន្តែអាចមានលទ្ធភាពចូលមើលទិន្នន័យពេញលេញគ្រប់ពេលវេលា និងស្វែងរកការផ្តល់ជូននៅពេលពួកគេត្រូវការបាន។

បន្ថែមលើសិក្ខាសាលាទីពីរ ក្រុមហ៊ុន Proact IT បានស្ម័គ្រចិត្តរៀបចំគំរូដើមមូលដ្ឋានមួយ និងដាក់ស្នើសេវារបស់ខ្លួនដើម្បីអភិវឌ្ឍកម្មវិធីសម្រាប់វេទិកា។ ការសម្រេចចិត្តបន្ទាន់មួយត្រូវបានធ្វើឡើងពាក់ព័ន្ធនឹងគោលបំណងធ្វើប្រតិបត្តិការវេទិកានៅលើអ៊ីនធឺណិត សម្រាប់ការប្រមូលផលនៅរដូវសំណើមនៅឆ្នាំ 2016 ដើម្បីរៀបចំអ្នកផ្តល់សេវានេះ។

លក្ខណៈពិសេសនៃកំណែដំបូងរបស់សុហ្វវែរនេះ ត្រូវបានបង្កើតឡើងដោយពិចារណាអំពីលទ្ធផលរបស់សិក្ខាសាលាទាំងពីរនេះ។ កិច្ចសន្យាជាមួយក្រុមហ៊ុន Proact IT ត្រូវបានធ្វើឡើងដោយផ្អែកលើព័ត៌មានលម្អិតដែលបានឯកភាពទាំងនេះ។ លក្ខណៈពិសេសសំខាន់ៗនៃវេទិកាត្រូវបានរៀបរាប់នៅក្នុងប្រអប់ 1 ខាងក្រោម។

**ប្រអប់ 1 ៖ លក្ខណៈពិសេស និងមុខងារសំខាន់ៗនៃវេទិកាស្តីពីពាណិជ្ជកម្មស្រូវកម្ពុជា**

អង្គការ FO ដែលចុះឈ្មោះក្នុងប្រព័ន្ធអាចបង្ហោះការប្រកាស (មុនពេលប្រមូលផលស្រូវសើម ឬមុនពេលឬបន្ទាប់ពីប្រមូលផលស្រូវស្ងួត) អំពីស្រូវដែលគេរំពឹងថាអាចលក់បាន។ ការប្រកាសបង្ហាញពីប្រភេទពូជស្រូវ (អង្ករផ្កាម្លិះ អង្ករក្រអូប អង្ករស) បរិមាណដែលរំពឹងទុក ប្រភពនៃគ្រាប់ពូជដែលប្រើសម្រាប់ផលិតកម្ម និងរយៈពេលនៃការប្រមូលផលដែលរំពឹងទុក (ឬ ភាពអាចរកបាននៃស្រូវ) និងប្រសិនបើគេរំពឹងថាមានការលក់ចេញស្រូវសើម ឬស្រូវស្ងួត។

ដោយសារតែអ្នកប្រើប្រាស់របស់អង្គការ FO បានចុះឈ្មោះជាមួយប្រវត្តិរូបរបស់ពួកគេរួចរាល់ហើយ រាល់ពេលពួកគេបង្ហោះការប្រកាស វានឹងភ្ជាប់មកជាមួយទីតាំងរបស់អង្គការ FO និងបុគ្គលទំនាក់ទំនងរបស់អ្នកដឹកនាំ/អ្នកតំណាងរបស់អង្គការ FO ។

ម្ចាស់រោងម៉ាស៊ីនកិនស្រូវ/ក្រុមហ៊ុននាំចេញដែលបានចុះឈ្មោះក្នុងប្រព័ន្ធ (ហើយមានឈ្មោះអ្នកប្រើប្រាស់ និងពាក្យសម្ងាត់) អាចចូលមើលព័ត៌មានតាមអ៊ីនធឺណិតលើវេទិកាលើអ៊ីនធឺណិតបាន។ ពួកគេអាចច្រោះទិន្នន័យទៅតាមលក្ខណៈវិនិច្ឆ័យដែលពួកគេចង់បាន (ឧទាហរណ៍ ប្រភេទពូជស្រូវ ឬខេត្ត ឬបរិមាណទាបបំផុត ។ល។)។

ម្ចាស់រោងម៉ាស៊ីនកិនស្រូវ/ក្រុមហ៊ុននាំចេញក៏អាចទទួលបានការជូនដំណឹងអ៊ីមែល និង/ឬ SMS ដោយផ្ទាល់គ្រប់ពេលដែលអង្គការ FO បង្ហោះការប្រកាស។ ប្រសិនបើពួកគេមិនចង់ទទួលបានការជូនដំណឹងច្រើនពេកទេ ពួកគេអាចកំណត់ការជ្រើសរើសដោយខ្លួនឯងផ្អែកលើលក្ខណៈវិនិច្ឆ័យដូចគ្នាខាងលើ ឬពួកគេអាចបិទការជូនដំណឹង។

ទាំងការជូនដំណឹងពីទិន្នន័យលើអ៊ីនធឺណិត និងអ៊ីមែល/SMS អាចចូលមើលជាភាសាខ្មែរ និងអង់គ្លេសបាន។ អ្នកប្រើប្រាស់អាចកំណត់ចំណង់ចំណូលចិត្តភាសារបស់ពួកគេ។

ប្រសិនបើស្រូវមិនមានសម្រាប់ការលក់ទៀតទេ អង្គការ FO គួរតែបោះបង់ចោលការប្រកាស។

កិច្ចប្រជុំមួយបានធ្វើឡើងនៅក្នុងសហព័ន្ធ CRF (ជាមួយម្ចាស់រោងម៉ាស៊ីនកិនស្រូវ និងអ្នកតំណាងមួយចំនួនរបស់អង្គការ FO) នៅថ្ងៃទី 12 ខែតុលា ដើម្បីធ្វើការកែសម្រួលបន្តិចបន្តួចលើលក្ខណៈពិសេសលម្អិតទាំងនេះ។ សហព័ន្ធ

SCCRP ▪ ករណីសិក្សា

CRF បានចាប់ផ្ដើមបង្ហាញក្ដីព្រួយបារម្ភអំពីការចូលរួមរបស់ខ្លួននៅពេលនោះផងដែរ ហើយកិច្ចប្រជុំតាមដានមួយត្រូវបានរៀបចំក្នុងសហព័ន្ធ CRF ម្ដងទៀតនៅថ្ងៃទី 18 ខែតុលា ឆ្នាំ 2016 ជាមួយគម្រោង SCCRP និង អ្នកតំណាងក្រុមហ៊ុន Proact IT ដើម្បីពិភាក្សានិងឯកភាពលើតួនាទីនិងមុខងាររបស់ភ្នាក់ងារនីមួយៗក្នុងការរៀបចំវេទិកា PTP ។ លក្ខខណ្ឌក្នុងការចូលប្រើប្រាស់វេទិកាក៏ត្រូវបានពិភាក្សាផងដែរ ហើយគេបានយល់ស្របថា នៅអំឡុងដំណាក់កាលសាកល្បងដែលសេវាកម្មបានផ្ដល់ឱ្យដោយឥតគិតថ្លៃ (មិនគិតថ្លៃសេវា) និងដោយគ្មានការជំទាស់ ម្ចាស់រោងម៉ាស៊ីនកិនស្រូវ និងសមាជិកក្រុមហ៊ុននាំចេញនៃសហព័ន្ធ CRF នឹងត្រូវបានចុះឈ្មោះជាអ្នកប្រើប្រាស់ រួចហើយអាចចុះឈ្មោះចេញ ឬបោះបង់ជម្រើសជូនដំណឹងជា SMS និងអ៊ីមែលបាន។

អំឡុងពេលប្រជុំ គេបានព្យាករណ៍ដឹងថា ការផ្ទេរកម្មសិទ្ធិទៅឱ្យសហព័ន្ធ CRF បន្ទាប់ពីដំណាក់កាលសាកល្បងដំបូង និងចុងបញ្ចប់នៃគម្រោង SCCRP ក្នុងករណីដែលភាគីទាំងពីរឯកភាពគ្នាលើលក្ខណ្ឌនៃការផ្ទេរនេះ។ អនុស្សរណៈនៃការយោគយល់គ្នាមួយត្រូវបានរៀបចំសម្រាប់គោលបំណងនេះ ប៉ុន្តែវានឹងពាក់ព័ន្ធជាមួយផ្នែកសហប្រតិបត្តិការផ្សេងទៀតរវាងគម្រោង SCCRP និងសហព័ន្ធ CRF ហើយអាចនិយាយថាវានឹងត្រូវបានរៀបចំនៅពេលក្រោយ។ ការរួមចំណែកដ៏សំខាន់ដែលបានរំពឹងទុកពីសហព័ន្ធ CRF គឺដើម្បីផ្ដល់បញ្ជីឈ្មោះម្ចាស់រោងម៉ាស៊ីនកិនស្រូវទាំងអស់ (ឬ អ្នកទិញស្រូវសក្ដានុពល) ក្នុងចំណោមសមាជិករបស់ខ្លួនទាំងអស់។ ភាពជាប់ពាក់ព័ន្ធនៃសហព័ន្ធ CRF ក្នុងវេទិកាស្ដីពីពាណិជ្ជកម្មស្រូវត្រូវបានលុបចោល ដោយសារតែសហព័ន្ធ CRF បានបដិសេធមិនផ្ដល់ទិន្នន័យទាំងនេះ។

គេក៏បានឯកភាពផងដែរក្នុងការវាយតម្លៃមួយ បន្ទាប់ពីដំណាក់កាលសាកល្បង ដើម្បីប្រមូលមតិយោបល់ពីអ្នកប្រើប្រាស់ និងកំណត់ការកែលម្អចាំបាច់ក្នុងការអភិវឌ្ឍលើកម្មវិធីដែលមានកំណែ 2.0 ព្រមទាំង (បើចាំបាច់) កែលម្អគុណភាព / ភាពអាចទុកចិត្តបាន / ការផ្ទៀងផ្ទាត់លើការបង្ហោះទិន្នន័យ។ គេបានបង្កើតវិធានរបស់អ្នកប្រើប្រាស់ឡើង ដើម្បីដោះស្រាយបញ្ហាជាក់ស្ដែងដែលកើតក្នុងអំឡុងពេលដំណើរការសាកល្បងនេះ។

ការបង្កើតកម្មវិធីអេឡិចត្រូនិក បានអនុវត្តតាមវិធីសាស្ត្រមួយដែលជំរុញលក្ខណៈពិសេស និងការពិចារណាពីតម្រូវការរបស់ភាគីពាក់ព័ន្ធក្នុងការបង្ហោះ មើល និងឆ្លើយតបទៅការប្រកាស។ ការចែកចាយរួមបញ្ចូលនូវកំណែនៃកម្មវិធីដែលបានដាក់ពង្រាយនៅក្នុងផលិតកម្ម ច្បាប់ចម្លងនៃលេខកូដប្រភព ការបន្ថែមតេស្តមុខងារ និងឯកសារផ្នែកបច្ចេកទេស។ កំណែសាកល្បងនៃវេទិកានេះត្រូវបានធ្វើតេស្ត ដើម្បីកំណត់អត្តសញ្ញាណនិងដោះស្រាយ "កំហុស" ទាំងអស់នៅចន្លោះថ្ងៃទី 26 និង 26 ខែតុលា។

## 4.2. ការរៀបចំ "មគ្គុទេសក៍សម្រាប់អ្នកប្រើប្រាស់"៖

ដំបូងឡើយ នៅពេលវេទិកា PTP លើអ៊ីនធឺណិតត្រូវបានផ្ដើមឡើង មគ្គុទេសក៍សម្រាប់អ្នកប្រើប្រាស់របស់វេទិកាស្ដីពីពាណិជ្ជកម្មស្រូវ (កំណែ 1.0) គ្រប់ជ្រុងជ្រោយមួយ ត្រូវបានរៀបចំជាភាសាអង់គ្លេស។ ការបកប្រែជាភាសាខ្មែរត្រូវបានធ្វើឡើងនៅមួយសប្ដាហ៍បន្ទាប់។

## 4.3. ការបើកដំណើរការវេទិកា PTP តាមអ៊ីនធឺណិត និងការបណ្តុះបណ្តាលអ្នកប្រើប្រាស់៖

វេទិកា PTP ត្រូវបានដាក់ឱ្យដំណើរការនៅលើអ៊ីនធឺណិតនៅថ្ងៃទី 27 ខែតុលា ឆ្នាំ 2016 ។ ការធ្វើបទបង្ហាញសង្ខេប ដែលរួមមាន ការបង្ហាញអំពីរបៀបប្រើប្រាស់វេទិកា និងរបៀបបង្ហោះការប្រកាសលក់ស្រូវ ត្រូវបានធ្វើនៅថ្ងៃបន្ទាប់ សម្រាប់អ្នកតំណាងសហព័ន្ធអង្គការ FO និងសមាជិកបុគ្គលិក។ អង្គការ FO ចំនួន 94 (អង្គការ FO ចំនួន 44 មាននៅក្នុងបញ្ជីឈ្មោះ និងអង្គការ FO ចំនួន 50 ទៀតមកពីការប៉ាន់ស្មានរបស់ FAEC, FCFD, FWN ដោយផ្អែកលើសក្តានុពលផលិតកម្មស្រូវអង្ករសម្រាប់ការធ្វើពាណិជ្ជកម្ម និងអង្គការ FO ចំនួនពីរដែលមានការគាំទ្រពី VSO ក្នុងខេត្តបាត់ដំបង) បានទទួលឈ្មោះប្រើប្រាស់និងពាក្យសម្ងាត់របស់ខ្លួន ដើម្បីចុះឈ្មោះចូលក្នុងប្រព័ន្ធ។ នៅចន្លោះដំណាច់ខែតុលា ឆ្នាំ 2016 ពេលវេទិកាត្រូវបានដាក់ដំណើរការលើអ៊ីនធឺណិត ហើយរហូតដល់ចុងបញ្ចប់នៃខែមីនា ឆ្នាំ 2017 អង្គការ FO ចំនួន 32 បានបង្ហោះការប្រកាសរបស់ខ្លួន។

ដោយសារសហព័ន្ធ CRF មិនបានផ្ញើឈ្មោះទំនាក់ទំនងរបស់ម្ចាស់រោងម៉ាស៊ីនកិនស្រូវ និងក្រុមហ៊ុននាំចេញ ក្រុមការងាររបស់គម្រោង SCCRP បានចុះឈ្មោះតែម្ចាស់រោងម៉ាស៊ីនកិនស្រូវ ឬក្រុមហ៊ុននាំចេញដែលមានឈ្មោះទំនាក់ទំនង និងក្រុមហ៊ុននាំចេញទាំងអស់ដែលឈ្មោះទំនាក់ទំនងរបស់ខ្លួនត្រូវបានបង្ហាញក្នុង "ការបូកសរុបក្រុមហ៊ុននាំចេញស្រូវកម្ពុជា" ដែលត្រូវបានរៀបចំឡើងដោយមានការគាំទ្រពីគម្រោង IFC សម្រាប់ព្រឹត្តិការណ៍ផ្សព្វផ្សាយនាំចេញទៅអន្តរជាតិ។ ឈ្មោះទំនាក់ទំនងថ្មីៗមួយចំនួនដែលបានពីគម្រោង SCCRP ពេលចូលរួមព្រឹត្តិការណ៍នេះក៏ត្រូវបានដាក់បញ្ចូលក្នុងបញ្ជីផងដែរ។ ក្រុមហ៊ុន Proact IT បានចុះឈ្មោះម្ចាស់រោងម៉ាស៊ីនកិនស្រូវប្រហែល 50 ដោយភាគច្រើនពាក់ព័ន្ធនឹង "អ្នកទិញ" ក្នុងប្រព័ន្ធ។ បន្ទាប់មកក្រុមការងាររបស់គម្រោងបានផ្ញើច្បាប់ចម្លងមគ្គុទ្ទេសក៍សម្រាប់អ្នកប្រើប្រាស់ទៅអ្នកទិញទាំងនោះ ដោយភ្ជាប់ជាមួយឈ្មោះអ្នកប្រើប្រាស់ និងពាក្យសម្ងាត់។ ចាប់ពីថ្ងៃទី 31 ខែតុលា ឆ្នាំ 2016 មក ពួកគេភាគច្រើនបានបើកការជូនដំណឹងជាអ៊ីមែល និងសារ SMS (តាមលំនាំដើម) របស់ខ្លួន លើកលែងតែក្រុមហ៊ុនមួយដែលគេមិនចង់ទទួលការជូនដំណឹងនោះ។

## 4.4. ប្រតិបត្តិការ ការតាមដានលើសារៈប្រយោជន៍ និងរក្សាការផ្តល់សេវាកម្ម



ការប្រកាសលក់ស្រូវរបស់អង្គការ FO ត្រូវបានបង្ហោះ និងលុបចេញដោយមន្ត្រីសហព័ន្ធអង្គការ FO ក្នុងនាមជាអង្គការ FO ។ ស្របគ្នានេះដែរ មន្ត្រីសហព័ន្ធអង្គការ FO បានផ្តល់ការងារដ៏សំខាន់ក្នុងការប្រាស្រ័យទាក់ទងជាមួយអ្នកតំណាងអង្គការ FO ដើម្បីធានាគុណភាព និងភាពត្រឹមត្រូវនៃទិន្នន័យដែលបានផ្តល់។ វាក៏ត្រូវបានផ្ទៀងផ្ទាត់នៅដំណាក់កាលលើកក្រោយនៅពេលនិយាយទៅម្ចាស់រោងម៉ាស៊ីនកិនស្រូវមួយចំនួនដែលចង់សួរសំណួរអង្គការ FO ផងដែរ។




ទីប្រឹក្សារបស់គម្រោង SCCRP បានលើកកម្ពស់សារៈប្រយោជន៍របស់វេទិកានេះទៅដល់សហព័ន្ធអង្គការ FO (CFAP និង FNN) ដោយព្យាយាមទទួលបានអង្គការ FO ដែលបានចាប់អារម្មណ៍បន្ថែមទៀតឱ្យចូលរួម។ ខណៈដែលមានការឯកភាពលើសារៈប្រយោជន៍នៃសេវាកម្មទាំងនេះ សហព័ន្ធទាំងនេះមិនបានជំរុញសមាជិករបស់ខ្លួនឱ្យចុះឈ្មោះទេ។

គេអាចទិញ ឬមិនទិញស្រូវ បន្ទាប់ពីការទំនាក់ទំនងតាមរយៈវេទិកាត្រូវបានផ្ទៀងផ្ទាត់ដោយការនិយាយទៅអ្នកតំណាងអង្គការ FO និងតាមរយៈរបាយការណ៍របស់សហព័ន្ធអង្គការ FO ។

មុនពេលសរសេរឯកសារអំពីការសិក្សាករណីនេះ ម្ចាស់ម៉ាស៊ីនរោងកិនស្រូវចំនួនប្រាំបួននាក់ត្រូវបានសម្ភាសន៍ក្នុងការវាយតម្លៃការប្រើប្រាស់វេទិកា PTP សម្រាប់គោលបំណងបន្ថែម ដើម្បីប្រមូលយកលក្ខណៈវិនិច្ឆ័យរបស់ពួកគេ ក្នុងការកែលម្អភាពដែលអាចរកបានព័ត៌មាន និងទិន្នន័យ ដើម្បីកែតម្រូវយុទ្ធសាស្រ្តផ្គូរផ្គង នៅពេលគម្រោងបញ្ចប់ និងចេញជារបាយការណ៍។

## 5. លទ្ធផល និងស្ថានភាពប្រតិបត្តិការ

នៅចុងឆ្នាំ 2016 និងដើមឆ្នាំ 2017 លទ្ធផលនៃការគាំទ្រដល់ការធ្វើពាណិជ្ជកម្មស្រូវគឺមិនបានល្អតាមការរំពឹងទុកទេ។ បរិបទសេដ្ឋកិច្ច និងទីផ្សារដ៏តានតឹងសម្រាប់វិស័យស្រូវអង្ករក្នុងអំឡុងរយៈពេលនោះ បានពន្យល់ខ្លះៗពីការដាក់កម្រិតនៃការលក់ជារួមដោយ អង្គការ FO ។ ជាពិសេស ម៉ូដែល "ក្រុមលក់ស្រូវអង្ករ" (PSG) ដែលបានបង្កើតឡើងដោយបណ្តាញ FWN និងមជ្ឈមណ្ឌល ISC ជាមួយសហគមន៍ FWUCs មិនបានសម្រេចលទ្ធផលតាមការរំពឹងទុកចំពោះការប្រមូលផលក្នុងឆ្នាំ 2016 ទេ។ នៅត្រីមាសចុងក្រោយនៃឆ្នាំនេះ សហករ AC ចំនួន 11 នៃ FAEC និង FCFD មានបំណងរៀបចំក្រុម PSG សម្រាប់ការលក់ស្រូវជារួមទៅម្ចាស់រោងម៉ាស៊ីនកិនស្រូវតាមរយៈការជួបប្រជុំផ្ទួងផ្ទាល់ដែលរៀបចំដោយគម្រោង SCCRP ។ FAEC និង FCFD បានធ្វើការចចារលើកិច្ចសន្យាលក់ជាមួយម្ចាស់រោងម៉ាស៊ីនកិនស្រូវសម្រាប់សហករ AC ពីរនាក់ដែលលក់ចេញច្រើនជាង 1,400 តោនប៉ុណ្ណោះ។

ក្នុងរយៈពេលបួនខែ បន្ទាប់ពីការដាក់ឱ្យដំណើរការវេទិកា PTP ការប្រមូលផលស្រូវ/ការប្រកាសលក់ស្រូវចំនួន 32 ដងត្រូវបានបង្ហោះដោយអង្គការ FO សម្រាបចំនួនស្រូវសរុប 36,692 តោន។ ម្ចាស់រោងម៉ាស៊ីនកិនស្រូវប្រាំមួយនាក់បានធ្វើការទាក់ទងមកអង្គការ FO បន្ទាប់ពីទទួលបានការជូនដំណឹងអំពីការប្រកាស ប៉ុន្តែមិនមានកិច្ចព្រមព្រៀងណាមួយអាចធ្វើឡើងទេ ក្នុងអំឡុងពេលអនុវត្តការសាកល្បងនេះ។ ការសាកល្បងលើកដំបូងនេះមិនមានដំណើរការល្អប៉ុន្មានទេ ដោយសារតែវិស័យនេះកំពុងជួបវិបត្តិជាក់លាក់មួយ ជាមួយតម្លៃទាប និងការបញ្ជាទិញនៅមានកម្រិតពីម្ចាស់រោងម៉ាស៊ីនកិនស្រូវ។ អង្គការ FO បានលើកឡើងហេតុផលសំខាន់ពីរដែលមិនបានចុះកិច្ចព្រមព្រៀងជាមួយម្ចាស់រោងម៉ាស៊ីនកិនស្រូវ ទីមួយគឺភាពខុសគ្នានៃពេលវេលារវាងការប្រមូលផល និងការទិញ ហើយមិនមានកិច្ចព្រមព្រៀងសាមញ្ញណាមួយអាចសម្រេចបានលើតម្លៃល្អប្រសើរជាងតម្លៃដែលត្រូវបានបង់ដោយឈ្មួញកណ្តាលក្នុងតំបន់។

ការវាយតម្លៃលទ្ធផលមួយដែលបានធ្វើឡើងនៅខែមីនា ឆ្នាំ 2017 ។ មានប្រាំបួននាក់ (ក្នុងចំណោមម្ចាស់រោងម៉ាស៊ីនកិនស្រូវចំនួនដប់ប្រាំបីនាក់ដែលបានទាក់ទង) បានឆ្លើយតបទៅនឹងការសម្ភាស។ ខណៈពេលដែលបានលើកឡើងថាពួកគេដឹងច្បាស់ថាវេទិកា PTP ជាឧបករណ៍មានប្រយោជន៍មួយក្នុងការផ្តល់ជូនទិន្នន័យ និងព័ត៌មានត្រឹមត្រូវ ហើយពាក់ព័ន្ធ ពួកគេក៏បានស្នើសុំឱ្យកែលម្អប្រព័ន្ធដោយផ្តល់ឱ្យច្បាប់ចម្លងរឹងនៃកូនសៀវភៅណែនាំអ្នកប្រើ PTP ជូនពួកគេ និងរៀបចំការពន្យល់ណែនាំអំពីរបៀបប្រើប្រាស់វាផងដែរ។ សំខាន់ជាងនេះទៅទៀត មានប្រាំបីនាក់បានលើកឡើងថាឈ្មោះទំនាក់ទំនងប្រើក្នុងឧបករណ៍អ៊ីនធឺណិតមិនមែនជាមនុស្សត្រឹមត្រូវ ដើម្បីកំណត់គោលដៅទេ ហើយបានស្នើឱ្យបន្ថែមអាសយដ្ឋាន អ៊ីមែល និងលេខទូរស័ព្ទផ្សេងទៀតរបស់និយោជិតដែលទទួលបន្ទុកលើការផ្គត់ផ្គង់ និងការទិញស្រូវសម្រាប់ក្រុមហ៊ុនរោងម៉ាស៊ីនកិនស្រូវ។ មួយចំនួនទៀតក៏បានលើកឡើងពីឆន្ទៈរបស់ពួកគេក្នុងការបន្ថែមគុណភាពប្រើប្រាស់ផ្លូវ (អាចប្រើប្រាស់បានចំនួន 40 តោន) ដែលត្រូវផ្តល់ដោយអង្គការ FO និងភាពអាចរកបានចាំបាច់ចំពោះអ្នកតំណាងអង្គការ FO ក្នុងការធ្វើដំណើរទៅទីតាំងរោងម៉ាស៊ីនកិនស្រូវដោយមានគំរូស្រូវសម្រាប់ការធ្វើតេស្តគុណភាព និងការផ្សព្វផ្សាយ។

បញ្ជីអ្នកទិញស្រូវសក្ដានុពលនៅក្នុងវេទិកា PTP គឺត្រូវបានបែងចែកជាបីប្រភេទ៖ ម្ចាស់រោងម៉ាស៊ីនកិនស្រូវសកម្ម ម្ចាស់រោងម៉ាស៊ីនកិនស្រូវមិនសកម្ម និងក្រុមហ៊ុននាំចេញស្រូវ។ ការវាយតម្លៃបានបង្ហាញថា មានតែម្ចាស់រោងម៉ាស៊ីនកិនស្រូវសកម្មប៉ុណ្ណោះបានកំពុងស្វែងរកការប្រកាសលក់ស្រូវ ខណៈពេលដែលអ្នកផ្សេងទៀតមិនបានស្វែងរកទេ។ ភាពខុសគ្នាមួយរវាងម្ចាស់រោងម៉ាស៊ីនកិនស្រូវមិនសកម្ម និងម្ចាស់រោងម៉ាស៊ីនកិនស្រូវគឺថាម្ចាស់រោងម៉ាស៊ីនកិនស្រូវមិនសកម្មដែលបានផ្អាកសកម្មភាពរបស់ពួកគេ ដោយសារតែភាពខ្វះខាតទីផ្សារស្រូវអង្ករនៅឆ្នាំនឹង អាចនឹងបន្តនៅឆ្នាំក្រោយ) ប៉ុន្តែម្ចាស់រោងម៉ាស៊ីនកិនស្រូវវិញគឺបិទរហូត។ ការបិទរហូតនេះនឹងត្រូវបានលុបចេញពីបញ្ជីអ្នកប្រើប្រាស់។ ម្ចាស់រោងម៉ាស៊ីនកិនស្រូវដែលផ្អាកនោះនឹងត្រូវបានបិទការជូនដំណឹងតាមសារ SMS របស់ពួកគេ។

សហព័ន្ធ CRF ត្រូវបានផ្ដល់សិទ្ធិឱ្យធ្វើជាម្ចាស់វេទិកានេះ ដើម្បីផ្ដល់សេវាកម្មដល់សមាជិករបស់ខ្លួនក្នុងទំនាក់ទំនងរវាងអង្គការកសិករ និងម្ចាស់រោងម៉ាស៊ីនកិនស្រូវ។ គេបានបង្កើតវា និងផ្ដល់ជូនដោយឥតគិតថ្លៃទៅដល់សហព័ន្ធ CRF ប៉ុន្តែវាមិនបានបង្ហាញពីឆន្ទៈក្នុងការគាំទ្រដល់ការបើកសំណួររបស់វេទិកា PTP ឡើងវិញស្ដីពីភាពជាម្ចាស់នៃវេទិកាសម្រាប់និរន្តរភាពរបស់ខ្លួនទេ។ ទោះមានការទទួលស្គាល់អំពីអត្ថប្រយោជន៍នៃសហប្រតិបត្តិការរវាងអង្គការកសិករ និងអ្នកទិញស្រូវក៏ដោយ ក៏អង្គការកសិករនៅតែអាចទទួលបានការផ្ដល់ជូនតម្លៃបន្ថែមទៀត និងអាចមានការឃុបឃិតជាមួយម្ចាស់រោងម៉ាស៊ីនកិនស្រូវមួយចំនួន ដែលមិនអំណោយផលដល់សហព័ន្ធស្រូវអង្ករកម្ពុជា។ ដោយមានការព្រួយបារម្ភលើស្ថាប័នអន្តរជំនាញ សេវាកម្មនៃទំនាក់ទំនងរវាងក្រុមម្ចាស់ភាគហ៊ុនផ្សេងទៀតក្នុងអនុវិស័យស្រូវអង្ករបានបង្កើតគោលដៅពាក់ព័ន្ធសំខាន់ៗរបស់ខ្លួន និងបង្កើតភាពស្របច្បាប់របស់ខ្លួនផងដែរ។ អត្ថប្រយោជន៍រួមដែលបានពីកិច្ចសហប្រតិបត្តិការរវាងម្ចាស់រោងម៉ាស៊ីនកិនស្រូវ និងអង្គការ FO គឺដើម្បីសម្រេចបានអត្ថប្រយោជន៍ផ្នែកពាណិជ្ជកម្មរួមគ្នាផ្សេងៗ នៅក្នុងចំណាប់អារម្មណ៍រួមគ្នាលើការកែលម្អខ្សែសង្វាក់ផ្គត់ផ្គង់តាមការកាត់បន្ថយថ្លៃចំណាយលើការស្វែងរក និងការប្រមូល ព្រមទាំងតាមការសម្របសម្រួលការចូលប្រើព័ត៌មាន ដែលពិតជាមានតម្លៃនៅក្នុងបរិបទកម្ពុជាដែលប្រភពព័ត៌មាននៅមានកម្រិត ហើយនៅមានការចំណាយខ្ពស់លើការប្រមូលការផ្គត់ផ្គង់ស្រូវ។

# 6. ការវិភាគផ្នែកសេដ្ឋកិច្ច

## 6.1. អត្ថប្រយោជន៍ជាក់ស្ដែងនៅកម្រិតនៃការអនុវត្តសាកល្បង

ជាទូទៅ វេទិកាស្ដីពីពាណិជ្ជកម្មស្រូវមានគោលបំណងកែលម្អទំនាក់ទំនងរវាងអង្គការកសិករ និងម្ចាស់រោងម៉ាស៊ីនកិនស្រូវ ដើម្បីបង្កើនបរិមាណ និងតម្លៃស្រូវអង្ករកម្ពុជាដែលបានលក់ទៅម្ចាស់រោងម៉ាស៊ីនកិនស្រូវក្នុងតំបន់។ ចំពោះការសាកល្បងលើកដំបូង វេទិកាស្ដីពីពាណិជ្ជកម្មស្រូវមិនមានភាពជឿជាក់ខ្លាំងទេទាក់ទងនឹងសមត្ថភាពអង្គការ FO ក្នុងការកំណត់ឱកាសលក់បានល្អប្រសើរជាងមុន។ ប៉ុន្តែវាពិបាកក្នុងការសន្និដ្ឋានដែលថា ឧបករណ៍នេះគឺមិនចាំបាច់ ឬមិនសមរម្យ។ ការវាយតម្លៃបង្ហាញពីឆន្ទៈរឹងមាំពីម្ចាស់រោងម៉ាស៊ីនកិនស្រូវក្នុងការចូលរួមចែករំលែក និងដោះដូរទំនាក់ទំនង និងព័ត៌មានបន្ថែមទៀត។ ភាពនៅជិតគ្នានេះ នៅតែជាលក្ខណៈវិនិច្ឆ័យដ៏សំខាន់មួយ ដែលបានប្រើដោយម្ចាស់រោងម៉ាស៊ីនកិនស្រូវក្នុងការជ្រើសរើសអង្គការ FO ឱ្យមកត្រួតពិនិត្យ និងការបង្ហាញពីឆន្ទៈរបស់ពួកគេក្នុងការពង្រីកការចូលប្រើវេទិកា PTP ទៅអង្គការ FO បន្ថែមទៀត។

អត្ថប្រយោជន៍ចម្បងរបស់វេទិកា PTP គឺជាលទ្ធភាពចូលប្រើរបស់វាចំពោះចំនួនជាច្រើននៃអ្នកប្រើប្រាស់ អង្គការ FO និងម្ចាស់រោងម៉ាស៊ីនកិនស្រូវ ហើយអាចធ្វើឱ្យអង្គការ FO និងម្ចាស់រោងម៉ាស៊ីនកិនស្រូវទាំងអស់ចូលរួមក្នុងប្រតិបត្តិការខ្សែសង្វាក់តម្លៃស្រូវ។ ប្រសិទ្ធភាពថ្លៃចំណាយរបស់វាបានធ្វើឱ្យសេដ្ឋកិច្ចដំណើរការល្អ និងផ្ដល់ការលើកទឹកចិត្តទៅ

ម្ចាស់រោងម៉ាស៊ីនកិនស្រូវក្នុងការចូលរួមវេទិកា។ ដោយសារតែ លក្ខខណ្ឌមួយចំនួននៃការបរាជ័យទីផ្សារស្រូវក្នុងតំបន់ដែលបានកើតឡើងក្នុងដំណាក់កាលសាកល្បង ដូច្នេះគ្មានសេចក្ដីសន្និដ្ឋានណាមួយអាចធ្វើឡើងពីសកម្មភាពសាកល្បងទេ លើកលែងតែវិធីធ្វើឱ្យវាកាន់តែងាយស្រួលប្រើ និងរបៀបលើកកម្ពស់ការប្រើប្រាស់ និងប្រតិបត្តិការរបស់វា។

គេក៏ត្រូវពិចារណាលើប្រសិទ្ធភាពថ្លៃចំណាយនៃការចរចាជាមួយអង្គការ FO ដែលជាអ្នកផ្គត់ផ្គង់ថ្មីជំនួសឱ្យឈ្មួញកណ្ដាល ដែលពួកគេធ្លាប់ប្រើក្នុងការងារផងដែរ។ ក្នុងឆ្នាំ 2016 បរិមាណនៃការនាំចេញស្រូវអង្ករកម្ពុជាមានចំនួនច្រើនជាងបន្តិចបើធៀបទៅនឹងឆ្នាំមុន។ ប្រសិនបើកំណើននៃការនាំចេញបន្តក្នុងឆ្នាំ 2017/2018 ម្ចាស់រោងម៉ាស៊ីនកិនស្រូវប្រហែលជានឹងត្រូវស្វែងរកប្រភពស្រូវថ្មី ហើយវានឹងក្លាយជាបរិបទល្អប្រសើរមួយសម្រាប់វេទិកា PTP ក្នុងការបង្ហាញពីផលប្រយោជន៍របស់ខ្លួន។ វាអាចជារឿងដ៏គួរឱ្យចាប់អារម្មណ៍ក្នុងការវិភាគទៅលើបរិមាណដែលបាននាំចេញពីក្រុមហ៊ុនមួយទៅក្រុមហ៊ុនមួយក្នុងរយៈពេលបីឆ្នាំចុងក្រោយនេះ (2014, 2015, 2016) ដើម្បីគាំទ្រដល់សហព័ន្ធអង្គការ FO ក្នុងការកំណត់អត្តសញ្ញាណម្ចាស់រោងម៉ាស៊ីនកិនស្រូវ ជាក្រុមហ៊ុននាំចេញដែលមានភាពរីកចម្រើនលឿនជាងគេ ហើយក៏ជាត្រូវបានចាប់អារម្មណ៍ក្នុងការស្វែងរកដំណោះស្រាយថ្មីសម្រាប់ស្វែងរកប្រភពស្រូវផងដែរ។ ជាមួយនឹងការកែលម្អស្ថានភាពអាជីវកម្មស្រូវអង្ករទូទៅពោរពេញដោយក្ដីសង្ឃឹមនេះ គេរំពឹងថាវេទិកា PTP ដែលបានធ្វើឱ្យល្អប្រសើរនេះនឹងផ្ដល់ភាពជោគជ័យក្នុងរយៈពេលខ្លីទៀត មុនពេលគម្រោង SCCRP បានបញ្ចប់។

## 6.2. ថ្លៃចំណាយដើម្បីផ្គត់ផ្គង់វេទិកា PTP

អត្ថប្រយោជន៍ចម្បងនៃការសម្រុះសម្រួលរវាងអាជីវកម្មលើអ៊ីនធឺណិតគឺជាការកាត់បន្ថយថ្លៃចំណាយស្វែងរក ដែលមានសារៈសំខាន់ជាពិសេសនៅក្នុងបរិបទប្រទេសកម្ពុជាលើការផ្គត់ផ្គង់ និងតម្រូវការដាច់ដោយឡែក និងប្រភពព័ត៌មាននៅមានកម្រិតសម្រាប់អ្នកប្រកបរបរខ្នាតមធ្យម និងខ្នាតតូច SME (រួមមានសហករ A-C ជាដើម) ។

សម្រាប់ដំណាក់កាលសាកល្បង ពាក់ព័ន្ធនឹងតម្រូវការក្នុងការបង្ហាញអត្ថប្រយោជន៍ឧបករណ៍ដល់អ្នកប្រើប្រាស់ និងអត្ថប្រយោជន៍ចំពោះភាគីទាំងអស់អាស្រ័យលើចំនួនអ្នកប្រើប្រាស់គ្រប់គ្រាន់ គេឯកភាពថា សេវានេះគឺបានផ្ដល់ឱ្យដោយឥតគិតថ្លៃ (គ្មានការបង់ប្រាក់លើថ្លៃសេវា) ។ ដំបូង គេប៉ាន់ស្មានថា ដោយគ្មានការជំទាស់ពីសមាជិកម្ចាស់រោងម៉ាស៊ីនកិនស្រូវ និងក្រុមហ៊ុននាំចេញទាំងអស់អាចនឹងចុះឈ្មោះក្លាយជាអ្នកប្រើប្រាស់ ហើយអាចចុះឈ្មោះចេញ ឬបោះបង់ជម្រើសនៃការជូនដំណឹងតាមសារ SMS និងអ៊ីមែល។ សូម្បីតែអ្នកដែលមិនមែនជាសមាជិកសហព័ន្ធ CRF ក៏អាចមានសិទ្ធិបន្ថែមក្នុងសេវាកម្ម ប្រសិនបើពួកគេស្នើសុំ ដើម្បីទាក់ទាញពួកគេឱ្យចូលរួមសហព័ន្ធ CRF ក្នុងករណីសេវាកម្មនេះត្រូវដាក់កម្រិតលើសមាជិកនៅពេលក្រោយ។ គេប៉ាន់ស្មានថា វានឹងមានអ្នកសម្របសម្រួលសហព័ន្ធ CRF សម្រាប់ការផលិត និងគ្រាប់ពូជស្រូវ ExCo ដែលជាអ្នកសម្របសម្រួលម្ចាស់រោងម៉ាស៊ីនកិនស្រូវ និងក្រុមហ៊ុននាំចេញ ពួកគេក៏ត្រូវការជំនួយក្នុងការលុបចោលការចុះឈ្មោះ ឬការបោះបង់ការជូនដំណឹងជា SMS ឬអ៊ីមែល។ ឈ្មោះទំនាក់ទំនងរបស់គាត់អាចត្រូវបានផ្ដល់ឱ្យក្នុងការប្រកាសដែលបានផ្ញើទៅម្ចាស់កិនស្រូវ ឬក្រុមហ៊ុននាំចេញ។

ក្នុងដំណើរការយូរជាងនេះទៀត ដើម្បីផ្គត់ផ្គង់សេវាកម្មនេះ ជម្រើសមួយក្នុងចំណោមជម្រើសប៉ាន់ស្មានផ្សេងទៀត គឺដើម្បីដាក់បញ្ចូលថ្លៃចំណាយលើសមាជិកភាពរបស់សហព័ន្ធ CRF ប្រសិនបើសហព័ន្ធ CRF ចង់បានដូច្នេះ ហើយគិតថ្លៃចំពោះតែអ្នកដែលមិនមែនជាសមាជិកក្នុងតម្លៃសមរម្យមួយ។ វានឹងត្រូវបានពិភាក្សាបន្ថែមទៀត អំឡុងពេលដំណាក់កាលសាកល្បងជាលើកដំបូង។ ទោះជាយ៉ាងណាក៏ដោយ សហព័ន្ធ CRF បានបដិសេធការសហការគ្នានៅ

ពេលចាប់ផ្តើម ការរៀបចំស្ថាប័នត្រូវតែកែប្រែឡើងវិញ ដើម្បីទ្រទ្រង់វេទិកានេះ។ គេបានស្នើជម្រើសផ្សេងទៀតនៅក្នុងជំពូកទី 7 ខាងក្រោមនេះ។

ផ្នែកជំនួយបច្ចេកទេសសំខាន់ៗគឺមានភាពចាំបាច់ ដើម្បីជួយដល់អង្គការ FOs ក្នុងការផ្តល់ជូនទិន្នន័យ និងព័ត៌មានត្រឹមត្រូវ។ គេគួរតែពិចារណាលើការបញ្ជូនផ្នែកមួយនៃថវិកាទៅសហព័ន្ធអង្គការ FO ដើម្បីទ្រទ្រង់តួនាទីចាំបាច់របស់ពួកគេលើការគាំទ្ររបស់អង្គការ FO ។

គេបានប៉ាន់ប្រមាណថ្លៃចំណាយក្នុងការផ្គត់ផ្គង់វេទិកាដោយគ្មានការដំឡើងជំនាន់បន្ថែមក្នុងតារាងទី 2 ខាងក្រោម។

**តារាងទី 2៖ តម្លៃប៉ាន់ប្រមាណដើម្បីទ្រទ្រង់ដល់ប្រតិបត្តិការនៃវេទិកាស្តីពីពាណិជ្ជកម្មស្រូវ**

| ការបរិយាយ | ឯកតា | | # ចំនួន | តម្លៃ | សរុប (USD) |
|---|---|---|---|---|---|
| ថ្លៃលើសេវាកម្មព័ត៌មានវិទ្យាសម្រាប់ការថែទាំ | ថ្ងៃធ្វើការ | | 3 | 250.00 US$ | 750.00 US$ |
| ការរក្សាទុកកម្មវិធី (រយៈពេល 1 ឆ្នាំ) ខែវិច្ឆិកា ឆ្នាំ 2017 ដល់ខែតុលា ឆ្នាំ 2018 | ឆ្នាំ | | 1 | 300.00 US$ | 300.00 US$ |
| សេវាកម្ម SMS សរុប* | | | | | 5,040.00 US$ |
| SMS ជាភាសាខ្មែរ | Nb នៃ SMS | (200 × 90) | 18,000 | 0.27 US$ | 4,860.00 US$ |
| SMS ជាភាសាអង់គ្លេស | Nb នៃ SMS | (200 ×10) | 2,000 | 0.09 US$ | 180.00 US$ |
| **ថ្លៃចំណាយសរុបលើប្រតិបត្តិការដើម្បីទ្រទ្រង់ប្រព័ន្ធ៖** | | | | | **6,090.00 US$** |

* ផ្អែកលើសម្មតិកម្មនៃការប្រកាសចំនួន 200 ក្នុងមួយឆ្នាំ ដែលបញ្ជូនបន្តទៅដល់អ្នកទិញសក្តានុពលចំនួន 100 (90 ជាភាសាខ្មែរ និង 10 ជាភាសាអង់គ្លេស) ។

ថ្លៃចំណាយខាងលើមិនរាប់បញ្ចូលសេវាកម្មព័ត៌មានវិទ្យាក្នុងការដំឡើងជំនាន់អន្តរមុខ សម្រាប់ការបន្ថែមសមាជិកថ្មី ងាយស្រួលប្រើ ឬការកែប្រែទិន្នន័យរបស់សមាជិកទេ។ ការដំឡើងជំនាន់សំខាន់ៗក្នុងការកែលម្អអន្តរមុខសម្រាប់ភាពងាយស្រួលប្រើខាងក្រោម គឺត្រូវបានកំណត់។ គេគួរតែរៀបចំសេវាកម្មព័ត៌មានវិទ្យា សម្រាប់រយៈពេលប្រាំថ្ងៃធ្វើការផ្សេងទៀត៖

- កែសម្រួល / បន្ថែម "ម៉ូឌុល" អ្នកប្រើរបស់អង្គការ FO
- ចូលមើលការប្រកាសដោយមិនចាំបាច់ចុះឈ្មោះចូល
- បញ្ចូលភូមិ ឃុំ ស្រុក និងខេត្ត ដោយប្រើប្រាស់ឈ្មោះរដ្ឋបាលស្តង់ដារ
- ការបញ្ចូលហេតុផលជ្រើសរើសសម្រាប់អង្គការ FO នៅពេលបញ្ចប់ការប្រកាស
- បញ្ចូលរូបភាពសម្រាប់ស្រូវសើម ឬស្ងួត
- ចូលប្រើប្រវត្តិនៃការប្រកាស
- បញ្ចូលនីតិវិធីរដ្ឋបាល នៅពេលប្តូរ ឬភ្លេចពាក្យសម្ងាត់

ថវិកាលើ SMS នៃដំណាក់កាលសាកល្បង គឺគ្រប់គ្រាន់សម្រាប់គ្របដណ្តប់លើថ្លៃចំណាយនៃសេវាកម្ម SMS រហូតដល់ដំណាច់ខែតុលា ឆ្នាំ 2017 ។ ប៉ុន្តែ ថ្លៃចំណាយទាំងនេះអាចត្រូវបានកាត់បន្ថយយ៉ាងច្រើន ប្រសិនបើបានរក្សាទុកវាចេញពីប្រទេសកម្ពុជា។ វេទិកាមួយឈ្មោះ PLAS-Gate ក្រោមការអភិវឌ្ឍរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង

នេសាទ កំពុងទទួលបានការគិតថ្លៃ SMS ដោយឥតគិតថ្លៃពីក្រុមហ៊ុនសែលកាត និងក្រុមហ៊ុនស្មាត។ ស្ថានភាពស្រដៀងគ្នានេះត្រូវអាចត្រូវបានគម្រោង SCCRP ចរចា។ មធ្យោបាយមួយទៀតក្នុងការកាត់បន្ថយថ្លៃចំណាយ គឺត្រូវកាត់បន្ថយទំហំសារជាភាសាខ្មែរ ដោយសារសារ SMS ជាភាសាខ្មែរ ប្រើប្រាស់ទំហំច្រើនជាងសារ SMS ជាភាសាអង់គ្លេសចំនួនប្រាំមួយដង។

ថ្លៃចំណាយបន្ថែមខាងក្រោម (សូមមើលតារាងលេខ 3 ខាងក្រោម) គឺប្រើដើម្បីគាំទ្រដល់អង្គការ FO ចំពោះកិច្ចការរបស់ពួកគេក្នុងការផ្តល់ព័ត៌មាន និងទិន្នន័យត្រឹមត្រូវមានគុណភាព និងដើម្បីបង្កោះការប្រកាសរបស់អង្គការ FO ។ សិក្ខាសាលាស្តីពីការប្រឹក្សាយោបល់របស់ភាគីពាក់ព័ន្ធធម្មតា នឹងមានផលប្រយោជន៍ក្នុងការទាញយកមេរៀនដែលបានរៀន ប្រើប្រាស់លទ្ធផល និងពិនិត្យមើលការឌីហ្សាញ ក៏ដូចជាលក្ខណៈវិនិច្ឆ័យរបស់វេទិកា PTP ដើម្បីធ្វើការកែលម្អវេទិកានេះ។

**តារាងទី 3៖ ថវិកាបន្ថែមដែលចាំបាច់ក្នុងការផ្តល់នូវការការពារដល់អង្គការ FO សម្រាប់ការប្រើប្រាស់លើវេទិកា PTP និងការប្រឹក្សាយោបល់ដើម្បីធ្វើការកែលម្អ**

| ការបរិយាយ | ឯកតា | # ចំនួន | តម្លៃ | សរុប (USD) |
|---|---|---|---|---|
| ការការពាររបស់សហព័ន្ធអង្គការកសិករដល់អង្គការ FO | អង្គការ FO | 100 | 30.00 US$ | 3,000.00 US$ |
| សិក្ខាសាលាស្តីពីការប្រឹក្សាយោបល់របស់ភាគីពាក់ព័ន្ធ | សិក្ខាសាលា | 1 | 2,000.00 US$ | 2,000.00 US$ |

ក្នុងករណីសហគមន៍ FWUC ជាសមាជិករបស់បណ្តាញ FWN នោះមជ្ឈមណ្ឌល ISC នឹងផ្តល់នូវសេវាកម្មរៀបចំការធ្វើផែនការប្រមូលផលស្រូវ ដែលតម្រូវឱ្យមានកាលវិភាគតាមលំដាប់នៃផលិតកម្ម និងការងាររបស់ក្រុមលក់ស្រូវ (PSG) ។ វាអាចធ្វើទៅរួច នៅពេលមានប្រព័ន្ធធារាសាស្ត្រ ហើយសហគមន៍ FWUC គឺមានសម្រាប់ផ្ទៃដីស្រោចស្រពមធ្យមចំនួន 1,600 ហិកតា ដែលផ្គត់ផ្គង់ស្រូវចំនួន 4,000 តោន។ ដូច្នេះ ស្រូវសម្រាប់ប្រើប្រាស់ក្នុងគ្រួសារត្រូវបានបន្ថយ ហើយបញ្ហាអភិបាលកិច្ចដែលកម្រិតលើប្រសិទ្ធពលរបស់ក្រុម PSG បានកាត់បន្ថយបរិមាណ (ជាតោន) នេះត្រឹមមួយភាគបី។ ការធ្វើបែបនេះនឹងផ្តល់ការលើកទឹកចិត្តគួរឱ្យចាប់អារម្មណ៍សម្រាប់ម្ចាស់រោងម៉ាស៊ីនកិនស្រូវ ដោយសារវាអនុញ្ញាតឱ្យមានការប្រកាសមុនដែលបញ្ជាក់អំពីកាលបរិច្ឆេទ និងចំណុចនៃការផ្គត់ផ្គង់នីមួយៗ ដែលធ្វើឱ្យការធ្វើផែនការដឹកជញ្ជូន និងដំណើរការមានប្រសិទ្ធភាព។ គេត្រូវពិចារណាលើថ្លៃចំណាយចំនួនពីរគឺថ្លៃចំណាយលើភស្តុភារ និងថ្លៃចំណាយផ្នែករដ្ឋបាលរបស់សហគមន៍ FWUC ក្នុងការសម្របសម្រួលដល់ការលក់ស្រូវ និងការជួយសម្រួលលើការរៀបចំផែនការលក់ស្រូវរបស់បណ្តាញ FWN/មជ្ឈមណ្ឌល ISC ដូចបានបង្ហាញក្នុងតារាងលេខ 4 ខាងក្រោម។

**តារាងទី 4៖ ថ្លៃចំណាយបន្ថែមសម្រាប់ការធ្វើផែនការប្រមូលផលលម្អិតបន្ថែម (ក្នុងករណីក្រុមលក់ស្រូវក្នុងសហគមន៍ FWUC)**

| ការបរិយាយ | ឯកតា | ថ្លៃចំណាយ (USD) |
|---|---|---|
| ការសម្របសម្រួលដោយអ្នកសម្របសម្រួលរបស់ក្រុម PSG (ពីកម្រិតចំណោញដែលបានធ្វើ) | តោន | 1.3 |
| កិច្ចការជួយសម្រួលដល់ការរៀបចំក្រុម PSG និងការធ្វើផែនការប្រមូលផល (ត្រូវមានការឧបត្ថម្ភ) | សហគមន៍ FWUC | 700 |

អត្ថប្រយោជន៍មួយទៀតរបស់វេទិកាលើអ៊ីនធឺណិត គឺអាចមានអ្នកប្រើអាចចូលប្រើបានយ៉ាងច្រើន ដូចជា អង្គការ FO និងម្ចាស់រោងម៉ាស៊ីនកិនស្រូវ។ ដូច្នេះ ការបែងចែងថ្លៃចំណាយក្នុងចំណោមអ្នកប្រើ គឺមានការពាក់ព័ន្ធគ្នា ដោយសារមានអ្នកប្រើសក្តានុពលជាច្រើនបានបន្ថយថ្លៃចំណាយនៅត្រឹមចំនួនទាបក្នុងអ្នកប្រើម្នាក់។ ការរ៉ាប់រងលើថ្លៃចំណាយទាំងនេះអាចត្រូវបានបែងចែកក្នុងចំណោមអង្គការ FO និងម្ចាស់រោងម៉ាស៊ីនកិនស្រូវ។ ទោះបីជាយ៉ាងនេះក្តី អង្គការ FO មានមូលនិធិមានកម្រិត ដែលបច្ចុប្បន្នត្រូវបានប្រើជាទុនវិនិយោគដើម្បីគ្របដណ្តប់លើប្រតិបត្តិការអាជីវកម្ម ហើយថ្លៃលើការវិនិយោគមុននៅក្នុងអាជីវកម្មសក្តានុពល មិនបានជួបប្រទះឡើយ។ ការគ្របដណ្តប់ជាក់ស្តែងរបស់អង្គការ FO គឺប្រើសម្រាប់មុខងារប្រមូល និងផ្តល់ទិន្នន័យនិងព័ត៌មាន។ ម្យ៉ាងវិញទៀត ម្ចាស់រោងម៉ាស៊ីនកិនស្រូវបានផ្តល់ការគាំទ្របានកាន់តែប្រសើរឡើងចំពោះថ្លៃចំណាយលើសេវាកម្មព័ត៌មានវិទ្យា ការរក្សាទុកទិន្នន័យ និង SMS ។ ថ្លៃចំណាយ SMS អាចត្រូវបានឧបត្ថម្ភដោយអ្នកផ្តល់សេវាកម្ម SMS ដូចដែលបានផ្តល់ឱ្យសម្រាប់ PLAS-Gate ។ ប៉ុន្តែការគាំទ្រពីខាងក្រៅសម្រាប់ការការពារដល់អង្គការ FO ក្នុងការបង្ហោះការប្រកាសរបស់ពួកគេ ក៏ដូចជានៅពេលចាំបាច់សម្រាប់ការរៀបចំការប្រឹក្សាយោបល់របស់ភាគីពាក់ព័ន្ធ និង/ឬ សម្រាប់ការរៀបចំផែនការលើការប្រមូលផលស្រូវ។ ដោយសារទាំងនេះគឺជាផ្នែកមួយនៃតួនាទីរបស់រាជរដ្ឋាភិបាលក្នុងការកំណត់ទិសដៅផលិតកម្ម និងសម្របសម្រួលដល់ការដំឡើងជំនាន់សង្វាក់តម្លៃស្រូវដើម្បីផលប្រយោជន៍សាធារណៈ ដូច្នេះគេត្រូវផ្តល់ការឧបត្ថម្ភដល់មុខងារនេះ។

## 7. ការគាំទ្រវេទិកា PTP បន្ថែមទៀត និងស្ថានភាពសម្រាប់និរន្តរភាព

ការសិក្សានៃការដំឡើង និងការអនុវត្តសាកល្បងនៃវេទិកាស្តីពីពាណិជ្ជកម្មស្រូវ បានកំណត់នូវសំណួរនាំមុខពីរគឺ៖

### តើគួរទម្លាក់ចោល ឬបន្តការផ្តួចផ្តើមគំនិតនេះ?

ភាពពាក់ព័ន្ធនៃឧបករណ៍នេះក្នុងការគាំទ្រដល់កំណើនសង្វាក់តម្លៃស្រូវអង្ករកម្ពុជា គឺត្រូវបានបង្ហាញបានយ៉ាងល្អ។ លទ្ធផលនៃការគាំទ្រដល់ពាណិជ្ជូបនីយកម្មស្រូវក្នុងឆ្នាំ 2016 គឺមិនល្អដូចការរំពឹងទុកទេ។ ស្ថានភាពសេដ្ឋកិច្ចលំបាក និងបរិបទទីផ្សារសម្រាប់វិស័យស្រូវអង្ករនៃឆ្នាំទាំងនេះ បានពន្យល់ដោយផ្នែកៗអំពីដែនកំណត់នៃការលក់រួមគ្នារបស់អង្គការ FO ។ ប៉ុន្តែ ទោះបីជាស្ថានភាពទីផ្សារអន្តរជាតិមានការលំបាកក៏ដោយ ក៏បរិមាណស្រូវដែលនាំចេញពីកម្ពុជាក្នុងឆ្នាំ 2016 នៅតែមានចំនួនស្រដៀងគ្នានឹងបរិមាណក្នុងឆ្នាំ 2015 ដែរ។ នេះសបញ្ជាក់ឱ្យឃើញថា ក្នុងករណីដែលស្ថានភាពទីផ្សារអន្តរជាតិសម្រាប់ស្រូវអង្ករបានប្រសើរឡើង នោះបរិមាណអង្ករដែលត្រូវនាំចេញនឹងកើនឡើង ហើយគេត្រូវស្វែងរកស្រូវកាន់តែច្រើនឡើង។

ការបង្ហាញឆន្ទៈរបស់ម្ចាស់រោងម៉ាស៊ីនកិនស្រូវមួយចំនួនក្នុងការដំឡើងជំនាន់ និងប្រើប្រាស់វេទិកា PTP បានបង្ហាញអំពីចំណាប់អារម្មណ៍ដ៏ខ្លាំងក្លា ដើម្បីបន្តការផ្តួចផ្តើមសាកល្បងនេះ។ នៅពេលវាយតម្លៃអំពីការប្រើប្រាស់វេទិកា PTP ក្នុងអំឡុងកិច្ចពិភាក្សាជាមួយម្ចាស់រោងម៉ាស៊ីនកិនស្រូវ ពួកគេបានបង្ហាញនូវវិធីនានាក្នុងការដំឡើងជំនាន់វេទិកានៅលើអ៊ីនធឺណិត ហើយសំណើដ៏មានសារៈសំខាន់គឺការអនុញ្ញាតឱ្យម្ចាស់រោងម៉ាស៊ីនកិនស្រូវអាចបង្ហោះការប្រកាសអំពីតម្រូវការស្រូវរបស់ខ្លួនបាន។ បញ្ហានេះនៅមិនទាន់បានជួបប្រទះនៅឡើយទេ ហើយបញ្ហាគឺរបៀបបញ្ជូនការប្រកាសទាំងនេះមកវិញ ដោយសារអង្គការ FO មិនអាចចូលប្រើអ៊ីនធឺណិតបាន។ បច្ចុប្បន្ននេះ ជម្រើស SMS គឺជាជម្រើសដែលអាចទៅរួច ដោយសារថ្លៃចំណាយលើ SMS ជាភាសាខ្មែរ ត្រូវបានកាត់បន្ថយ។ ដោយសារម្ចាស់រោងម៉ាស៊ីនកិនស្រូវអាចបង្ហោះការប្រកាសញឹកញាប់ ដូច្នេះបច្ចុប្បន្នវាមានតម្លៃថ្លៃខ្លាំង។ ដំណោះស្រាយមួយទៀតត្រូវបានកំណត់

ពោលគឺទំព័រហ្វេសបុកអាចធ្វើឱ្យមានការទាក់ទាញ ប៉ុន្តែការបង្កើតឧបករណ៍បែបនេះនឹងតម្រូវឱ្យការវិភាគច្រើន និងការងាររៀបចំរៀបចំរយៈពេលវែង ដើម្បីស្របទៅតាមតម្រូវការនិងស្ថានភាពថ្មីៗ។

ខណៈដែលអ្នករាល់គ្នាបានឯកភាពថា បញ្ហាចម្បងនៃវិស័យស្រូវអង្ករនៅកម្ពុជា គឺការគ្រប់គ្រងសង្វាក់ផ្គត់ផ្គង់ ដូច្នេះការលើកកម្ពស់យន្តការថ្មីសម្រាប់បម្រើដល់ការដាក់បញ្ចូលទីផ្សារសម្រាប់កសិករដែលបារៀបចំឡើង គឺមានសារៈសំខាន់ខ្លាំង។ សម្រាប់រដូវប្រមូលផលស្រូវខាងមុខ គម្រោង SCCRP នឹងបន្តសាកល្បងវេទិកា PTP កំណែថ្មីដែលនឹងផ្តោតសំខាន់លើការផ្លាស់ប្តូរនានាដែលស្នើដោយអង្គការ FO និងម្ចាស់រោងម៉ាស៊ីនកិនស្រូវ។

- វិបសាយនឹងផ្តល់ជូនសេវាកម្មដល់អ្នកទិញស្រូវ ដើម្បីបង្ហោះការប្រកាសអំពីតម្រូវការរបស់ពួកគេ ដោយសារវាជាការងារលក់ស្រូវរបស់អង្គការ FO
- សហព័ន្ធអង្គការ FO នឹងជួបប្រជុំជាមួយម្ចាស់រោងម៉ាស៊ីនកិនស្រូវជាង 100 នៅដើមរដូវប្រមូលផល ដើម្បីផ្លាស់ប្តូរព័ត៌មាន និងដើម្បីណែនាំអំពីវេទិកា ដោយមានការរំពឹងទុកថាការរួមបញ្ចូលគ្នារវាងឧបករណ៍ផ្គូផ្គងទាំងពីរនេះនឹងបង្កើនឱកាសជោគជ័យ
- ម្ចាស់រោងម៉ាស៊ីនកិនស្រូវដែលចុះឈ្មោះនឹងទទួលបានច្បាប់ចម្លងគោលការណ៍ណែនាំវេទិកា PTP និងការបណ្តុះបណ្តាលអំពីរបៀបប្រើប្រាស់វិបសាយ
- សហព័ន្ធអង្គការ FO ក៏នឹងបណ្តុះបណ្តាលអង្គការ FO អំពីការប្រមូលទិន្នន័យត្រឹមត្រូវ និងបន្តការគាំទ្ររបស់ពួកគេដល់ការបង្ហោះការប្រកាសរបស់អង្គការ FO
- ធ្វើឱ្យប្រសើរឡើងបន្ថែមទៀតលើវេទិកានេះ ដូចជា ការផ្តល់ជូនបន្ទប់ជជែកកំសាន្តតាមអ៊ីនធឺណិតឬការបង្ហោះនៅលើហ្វេសប៊ុក នឹងត្រូវបានពិភាក្សា និងវិភាគនៅក្នុងដំណាក់កាលអនុវត្តសាកល្បងនេះ។

ទោះយ៉ាងណាក៏ដោយ ប្រសិនបើគ្មានការរៀបចំផ្នែកស្ថាប័នសមរម្យដើម្បីធានានិរន្តភាពនៃវេទិកានោះទេ នោះការធ្វើអន្តរាគមន៍នឹងមិនមានភាពរឹងមាំឡើយ។

## តើអ្វីជាលក្ខខណ្ឌសម្រាប់និរន្តរភាព?

សំណួរនេះមានសារៈសំខាន់នៅពេលគម្រោង SCCRP ត្រូវបញ្ចប់នៅខែធ្នូ ឆ្នាំ 2017 ជាការអនុវត្តវេទិកា PTP សាកល្បងនេះដែលបច្ចុប្បន្នកំពុងស្ថិតនៅក្រោមផ្នែកមួយនៃគម្រោងនេះ។ ទោះជាក្រុមការងារគម្រោង SCCRP ទទួលបានគំនិតផ្តួចផ្តើមពីវេទិកា PTP ហើយបាននាំមុខក្នុងការរៀបចំរបស់ខ្លួនក៏ដោយ ក៏គេមើលឃើញថាភាពជាម្ចាស់នៃវេទិកានេះអាចត្រូវបានផ្ទេរទៅសហព័ន្ធស្រូវអង្ករកម្ពុជា។ បន្ទាប់ពីនេះការគ្រប់គ្រងគម្រោងនេះ គឺ SNEC បានណែនាំឱ្យបន្តការអនុវត្តវេទិកាស្តីពីពាណិជ្ជកម្មស្រូវសាកល្បង ដោយមិនមានសហព័ន្ធ CRF ដែលស្ថិតក្រោមភាពជាម្ចាស់របស់គម្រោងសម្រាប់ដំណាក់កាលសាកល្បងជាលើកដំបូង និងក្នុងភាពជាដៃគូជាមួយសហព័ន្ធអង្គការ FO ដែលនៅខាងពួកគេបានផ្តល់បញ្ជីឈ្មោះអង្គការ FO ដែលពួកគេចង់ចុះឈ្មោះចូលជាអ្នកប្រើដោយតម្រូវឱ្យមានព័ត៌មានប្រវត្តិរូបលម្អិតទាំងអស់។

ដោយពិចារណាលើប្រវត្តិរូបនេះ គឺហាក់បីដូចជាមានតែបីជម្រើសប៉ុណ្ណោះសម្រាប់ការគ្រប់គ្រងវេទិកា PTP ៖

**ជម្រើសទី 1៖ ដាក់បញ្ចូលវេទិកា PTP ទៅក្នុងវេទិកា PLAS-Gate ដែលគ្រប់គ្រងដោយក្រសួង MAFF**

បច្ចុប្បន្ននេះ ការិយាល័យទីផ្សារកសិកម្ម (AMO) នៃនាយកដ្ឋានផែនការ និងស្ថិតិនៅក្រសួង MAFF កំពុងបង្កើតវេទិកាវិបសាយមួយដែលបំពេញបន្ថែមលើប្រព័ន្ធព័ត៌មានទីផ្សារកសិកម្មរបស់ក្រសួង MAFF ។ វេទិកា PTP អាចត្រូវបាន

ដាក់បញ្ចូលទៅក្នុងវេទិកានេះ។ ទោះជាយ៉ាងណាក៏ដោយ ជម្រើសនេះមិនអាចដោះស្រាយបញ្ហានេះក្នុងរយៈពេលខ្លីបានទេ ដោយសារតែការដាក់បញ្ចូលបែបនេះនឹងតម្រូវឱ្យមានសេវាកម្មផ្នែកព័ត៌មានវិទ្យាដ៏សំខាន់ ដើម្បីសម្រួលដល់វេទិកាទាំងពីរសម្រាប់សេវាកម្មដែលរំពឹងទុកយ៉ាងទូលំទូលាយ។ ប្រធានការិយាល័យ AMO របស់ក្រសួង MAFF នឹងត្រូវបានទាក់ទង ដើម្បីសិក្សាលទ្ធភាពនេះបន្ថែមទៀត។ សម្រាប់និរន្តរភាព បញ្ហានានាក៏ត្រូវបានដោះស្រាយផងដែរ ដើម្បីធានាឱ្យបាននូវលទ្ធភាពយូរអង្វែង។

1/ វេទិការបស់ការិយាល័យ AMO កំពុងផ្សព្វផ្សាយការផ្លាស់ប្ដូរផលិតផលជាច្រើន ដោយផ្អែកលើប្រព័ន្ធប្រមូលតម្លៃដែលបច្ចុប្បន្នត្រូវបានគាំទ្រតាមរយៈអ្នកឧបត្ថម្ភខាងក្រៅ។ លក្ខខណ្ឌត្រូវបានបញ្ជាក់ពីលទ្ធភាពផ្នែកហិរញ្ញវត្ថុរយៈពេលវែងដោយខ្លួនឯង ជាពិសេសពាក់ព័ន្ធនឹងការចូលរួមរបស់វិស័យឯកជន។

2/ វេទិការបស់ការិយាល័យ AMO បច្ចុប្បន្នមិនមានផែនការថែទាំ និងផែនការហិរញ្ញវត្ថុ ដើម្បីគាំទ្រវេទិកានេះទេ។

**ជម្រើសទី 2៖ តាមរយៈវេទិកាជាតិនៃសហព័ន្ធអង្គការ FO (វេទិការបស់សហព័ន្ធអង្គការ FO ជាតិ ហៅកាត់ថា "NF3"** ដែលបច្ចុប្បន្នកំពុងត្រូវបានបង្កើតដោយ FAEC, FCFD, FWN, FNN និង CFAP

បច្ចុប្បន្ន វេទិកានៃសហព័ន្ធអង្គការ FO ស្ថិតក្រោមការអភិវឌ្ឍ និងស្ថាបនាកម្មដែលហៅថា "NF3" ។ សហព័ន្ធអង្គការ FO បានជួបប្រជុំជាច្រើនដង ដើម្បីឯកភាពគ្នាលើលក្ខខណ្ឌសហប្រតិបត្តិការ និងការរួមចំណែកការងារ។ ប្រតិបត្តិការរបស់វេទិកា PTP អាចជាមុខងារជាក់ស្ដែងរបស់ NF3 ដែលអាចក្លាយជាអ្នកផ្សព្វផ្សាយគាំទ្រ/អ្នកការផ្សព្វផ្សាយគាំទ្រពេលដែលអនុវត្តមុខងារសហប្រតិបត្តិការដើម្បីដំណើរការវេទិកា PTP ។ ទោះជាយ៉ាងណាក៏ដោយវេទិកានៃសហព័ន្ធអង្គការ FO មិនទាន់បានដឹងពីសកម្មភាពសំខាន់ៗដែលត្រូវកំណត់ឱ្យមានភាពស្របច្បាប់ ដើម្បីគ្រប់គ្រងវេទិកា PTP ឡើយ។ ពួកគេនៅតែត្រូវការការសម្របសម្រួលពីខាងក្រៅ ដើម្បីបង្កើនការយល់ដឹង និងការជឿទុកចិត្ត ហើយពួកគេមិនតំណាងឱ្យរោងម៉ាស៊ីនកិនស្រូវទេ ប៉ុន្តែ វេទិកា PTP អាចត្រូវបានគេមើលឃើញថាជាឧបករណ៍មួយ ដើម្បីទទួលបានអំណាចចរចា និងពង្រឹងតួនាទីរបស់អង្គការ FO នៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់អង្ករ។

**ជម្រើសទី 3 ៖ តាមរយៈក្រុមការងារថ្មីដែលបង្កើតចេញពីអង្គការ FO និងរោងម៉ាស៊ីនកិនស្រូវ ត្រូវបានបង្កើតឡើង**

អ្នកតំណាងរោងម៉ាស៊ីនកិនស្រូវ និងអង្គការ FO មួយចំនួនបានសម្ដែងការព្រួយបារម្ភរបស់ខ្លួនដោយសារតែសហព័ន្ធ CRF មិនបានបង្ហាញឱ្យឃើញ និងការពារផលប្រយោជន៍នៃវិស័យអង្ករទាំងមូល ហើយមិនបានអនុវត្តសេវាកម្មជាក់ស្ដែងដល់សមាជិករបស់ខ្លួន។ ជាលទ្ធផលពួកគេនៅតែប្រតិបត្តិដាច់ដោយឡែកពីគ្នា ហើយការទុកចិត្ត និងកិច្ចសហប្រតិបត្តិការមិនបានបង្កើតឡើងក្នុងចំណោមភាគីពាក់ព័ន្ធទាំងនេះទេ។ ការខកខាននៃការចូលរួម និងជួបប្រជុំរបស់ផលិតកម្មសហព័ន្ធ CRF និង Milling ExCo ត្រូវបានគេលើកឡើងជាចំណុចខ្សោយមួយ។ រោងម៉ាស៊ីនកិនស្រូវអង្ករ និងអ្នកតំណាងអង្គការ FO បានស្នើសុំឱ្យគម្រោង SCCRP រៀបចំកន្លែងសន្ទនាជាផ្លូវការមួយទៀតដែលក្រុមសំខាន់នេះអាចរៀបចំយុទ្ធសាស្ត្រធ្វើឱ្យប្រសើរឡើងនៃខ្សែចង្វាក់តម្លៃស្រូវរួមគ្នា។ គំនិតនេះអាចត្រូវបានធ្វើឱ្យប្រសើរឡើងវិញនៅក្រោមការរៀបចំដោយប្រើវិធីសាស្ត្រស្នូល (/ ឬ "ប្រមូលផ្ដុំ") ។

ជម្រើសទាំងនេះមិនមែនជាជម្រើសដែលមានស្រាប់ទេ។ ជម្រើសទាំងនេះទាមទារឱ្យមានការលើកកម្ពស់ និងអនុវត្តតាមមួយជំហានម្ដងៗ ដើម្បីបង្កើតភាពសមរម្យ ភាពជាម្ចាស់ និងទំនុកចិត្ត។